និពន្ធដោយ **សួន ម៉ាក់**

*សមាជិកសមាគមអ្នកនិពន្ធខ្មែរ*

# មរណភាពនៅអារញ្ញ

(ប្រលោមលោកមនោសញ្ចេតនា អប់រំ ឆ្លុះបញ្ចាំងពីតថភាពសង្គមកម្ពុជាបច្ចុប្បន្ន)

# ទាចារអ្នកនិពន្ធ

ជីវិតហាក់បីដូចជាដុំផ្សែងដ៏ខ្ចលខ្ចាញ់ ដែលរសាត់អណ្តែតទៅតាមគំនួចវាយោ ហើយបក់ផាត់ពីកន្លែងមួយទៅកន្លែងមួយ ដោយគ្មានទិសដៅពិតប្រាកដ។ ឆាកជីវិតមនុស្សពិតជាមិនអាចស្មានត្រូវទេ ថ្ងៃនេះមានសេចក្តីសុខ ថ្ងៃស្អែកក៏មិនប្រាកដថាមានសេចក្តីទុក្ខដែរ... ចំពោះរឿងស្នេហាក៏ដូច្នោះដែរ ថ្ងៃនេះជួប ថ្ងៃស្អែកបែកក៏ថាបាន... សេចក្តីសុខ និង ទុក្ខតែងផ្លាស់វេនគ្នាជានិច្ច ។ ឆាកជីវិតមនុស្សព្រហ្មលិខិតជាអ្នកកំណត់ តែមនុស្សខ្លួនឯងក៏ត្រូវចេះប្រើសតិសម្បជញ្ញៈ សំរាប់ធ្វើជាចង្កូតបត់បែនគន្លងជីវិតរបស់ខ្លួនទៅតាមកាលៈទេសៈផងដែរ។

នៅពេលនេះ ប្រលោមលោករឿង "មរណៈភាពនៅអារញ្ញ" នឹងឆ្លុះបញ្ចាំងឱ្យឃើញពីតថភាពសង្គមកម្ពុជានាពេលបច្ចុប្បន្ន... ស្នេហាភក្តី ស្នេហាផិតក្បត់ ស្នេហាត្រីកោណ អំពើជួញដូរមនុស្ស ជួញដូរគ្រឿងញៀន ជំងឺអេដស៍ អំពើហិង្សា នឹងចូលខ្លួនមកផ្សំរសជាតិ ឱ្យប្រលោមលោកនេះមានគ្រប់ឱជារសទាំងអស់ ។

"មរណៈភាពនៅអារញ្ញ" ឆ្លុះបញ្ចាំងពីឆាកជីវិតពិត របស់នារីស្រុកស្រែម្នាក់ ដែលត្រូវគេបោកយកទៅលក់ ដោយសារតែភាពល្ងង់ខ្លៅ.....

" មរណៈភាពនៅអារញ្ញ " នឹងបង្ហាញពីជីវិតរស់នៅដ៏លំបាកវេទនារបស់ប្រជាជនខ្មែរ នៅទល់ដែនកម្ពុជា-ថៃ.... "មរណៈភាពនៅអារញ្ញ" មិនភ្លេចរំលេចអោយឃើញពីតំលៃនៃសីល និង ច្បាប់ក្នុងសង្គមកម្ពុជា តាមមាគ៌ាដឹកនាំរបស់រាជរដ្ឋាភិបាលឡើយ ។

"មរណៈភាពនៅអារញ្ញ" ក៏បង្ហាញអោយឃើញពីសោកនាដកម្មស្នេហាមួយ ដែលធ្វើអោយលោកអ្នកទប់ទឹកភ្នែកមិនបាន ហើយចងចាំវាទុកជាប់ជានិច្ច.... ហេតុនេះ តើសេចក្តីស្នេហាដែលផ្អែមល្ហែមដូចទឹកឃ្មុំ អាចក្លាយជាពិសពុល សំលាប់អ្នកដែលលង់ខ្លួនប្រលែងលេង នឹងល្បែងនេះដែររឺទេ ?...... ធម្មតាទឹកឃ្មុំតែងមានរសផ្អែមត្រជាក់ ផ្កាកុលាបតែងមានសម្រស់ និង ក្លិនក្រអូបប្រហើរ..... តែពេលនេះ ទាំងទឹកឃ្មុំ ទាំងផ្កាកុលាបប្រែជា មានពិសពុលធ្វើអោយអ្នកដែលប៉ះពាល់វា ចុកចាប់ពើតផ្សាបំផុត ។

ឱពិសទឹកឃ្មុំ ! ឱពិសស្នេហ៍កុលាប !..... ពេលនេះអ្នកមិនត្រឹមតែបំផ្លាញសុភមង្គល របស់មនុស្សអាក្រក់ប៉ុណ្ណោះទេ តែអ្នកថែមទាំងបំផ្លាញដួងចិត្ត និង បេះដូងបរិសុទ្ធរបស់បុរសម្នាក់ អោយខ្ទេចខ្ទាំចុកចាប់ក្រៃលែង។ សម្តីអូនប៉ុន្មានឃ្លាខាងលើនេះ បានធ្វើអោយបងស្លាប់ចិត្តទាំងរស់ បេះដូងបងដែលកំពុងពុះកញ្ជ្រោលដោយភ្លើងស្នេហ៍ ក៏ត្រូវរលត់ស្ងួនស្ងៀមដោយទឹកសម្តីប៉ុន្មានម៉ាត់នេះដែរ...។... កុំទៅណាចោលបងអី !... កុំទុកពេលវេលាមួយរាត្រីរបស់យើងថាជាការយល់សប្តិ... បងមិនដែលបំភ្លេចពេលវេលានោះ សូម្បីមួយ





វិនាទី បងមានការទទួលខុសត្រូវក្នុងនាមកូនប្រុស ហើយក៏ជាការទាមទារនៃបេះដូងបងផ្ទាល់ទៀតផង....។ អូនកុំចង់ប្រើពេលវេលាយ៉ាងខ្លីនេះមកកាត់ផ្តាច់ចំណងស្នេហ៍យើង... មិនមែនជាការងាយទេ សូម្បីតែសម្តីមួយម៉ាត់ ! សូម្បីតែសម្តីលាចុងក្រោយ !... ក៏អូនមិនបាន និយាយប្រាប់បងដែរ.....

ភ្នំពេញ ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០៦

អ្នកនិពន្ធ **សួង ម៉ាក់**

ទូរស័ព្ទ : ០១២ ៧៧៨ ១៥៣

## វគ្គទី១

# លាភូមិកំណើត

អរុណរះជះរស្មីក្រហមឆ្អិនឆ្អៅ កាត់ទំលុះស្លឹករុក្ខជាតិតូចធំ ចាំងចោលរស្មីព្រាកៗលើផ្ទៃទឹក ។ វាយោបក់មកត្រសៀកៗធ្វើអោយផ្ទៃគង្គាញ័ររំកិលជារលករលេញអង្គញអង្កាញ់ព្រិចៗដូចស្រកានាងទេពមច្ឆាជះរស្មីភ្លឺផ្លេក គួរឱ្យពិចពិលរមិលមើល ។ មើលហ្ន៎ ! លើផ្ទៃទឹកដ៏ថ្លាយង់មានលេចចេញជារូបស្រីម្នាក់សែនស្រស់សោភាបីដូចជាទេពអប្សរចុះពីឋានសួគ៌ាល័យ ។ នាងឈរលើស្ពានយ៉ាងស្ងៀមស្ងាត់ ខ្សែនេត្រាកំពុងគន់មើលស្រមោលភ័ក្ត្រខ្លួន ដែលឆ្លុះក្នុងផ្ទៃកញ្ចក់ធម្មជាតិ..... ។ យូរៗម្តង វាយោបក់ផាត់មកធ្វើអោយរលករត់មករមេញរលប់ស្រមោលនាងអោយរំពើតរំពើនរួចហួសទៅ ឯស្រមោលក៏មានភាពនឹងថ្កល់ឡើងវិញ ។ រលកមួយថ្មីក៏មកដល់ ហើយរុញស្រមោលនាងអោយរំពើតរំពើនម្តងទៀត.... តែកែវភ្នែកដ៏ខ្មៅក្រឹបរលីងរលោង ដោយទឹកភ្នែករបស់ម្ចាស់រូប ឥតព្រិចបន្តិចឡើយ ។ កែវភ្នែកទាំងគូនៅគន់មើលរូបខ្លួនដោយភ្លឹកភ្លាំង... វង់ភ័ក្ត្រស្រីដូចផ្ការីកប៉ប្រិម តែបែរជាជិតដាមនូវភាពស្រពោនចម្លែកធ្វើអោយសម្រស់ដ៏ផូរផង់នេះ ត្រូវធ្លាក់ចុះមួយកំរិត ។ ភ័ក្ត្រស្រីពេលនេះមិនខុសអ្វីពីស្រទាប់បុប្ផាដែលដាច់ទងជ្រុះចោលលើដី រងកំដៅសូរ្យសែងឡើងស្លោកក្រៀមក្រញូងឡើយ ។

ជូនជាមានខ្យល់ជំនោរបក់ផាត់មកប៉ះកាយស្រី សរសៃសក់ក៏តាំងប៉ើងរប៉ាត់រប៉ាយរេរាំតាមកំលាំងវាយោ ធ្វើអោយសក់រំសាយមកបបោសអង្អែលប្រលែងលេងនឹងខ្នងទេពកញ្ញា។ ពេលវេលាចេះតែរំកិល.... នាងក្រមុំនៅតែឈរធ្មឹងគ្មានកំរើក.... គ្មានវាចាមួយម៉ាត់ ភត្រ្តានៅតែស្ងប់ស្ងួតដដែល... ។

បុរសរូបសង្ហាតាមបែបអ្នកស្រែចំការម្នាក់ឋិតក្នុងវ័យប្រមាណ ២៥ឆ្នាំកំពុងលីនង្គ័លប្រលាក់ភក់ស្រមកដើរមករកតរុណី។ នរៈមានមាឌធំមាំខ្ពស់ស្រលះ គឺជាបុរសខ្មែរពេញអង្គ ចិញ្ចើមគេខ្មៅក្រើប ភ្នែកភ្លឺមុត ច្រមុះស្រួចបបូរមាត់ជិតដាមភាពញញឹមជានិច្ច សម្បុរសណ្តែកបាយ សក់រួញអង្គាជី ផ្ទៃមុខរាហ៍ផ្ចិតនូវស្នាមប្រជាប្រិយស្អាតអត់ទាស់។ ភាពឈរធ្មឹងរបស់ស្រស់កញ្ញាបានទាញជំហានបុរសអោយឈរង៉ក់ភាំងសំលឹងមកស្រី អត់ឆ្ងល់មិនបានមនោក៏សួរនាងដើម្បីទំលុះសភាពតានតឹងនេះ :

-វំដួល ! អូនមានរឿងអីហ្នឹងបានជាឈរស្ងប់ស្ងៀមយ៉ាងនេះ ?

ភ្ញាក់ព្រើត ! មាណវីងាកមករកម្ចាស់សំលេងទាំងភ័យញ័រតិចៗ :

-អ្ហូ ! បងមនោ បងមកឈរពីក្រោយអូនពីអង្កាល់ បានជាអូនមិនដឹងខ្លួនអ៊ីចឹង ?

ពេលដែលនាងងើបមុខឡើង សូម្បីអ្នកនិពន្ធយើង ក៏អត់ទ្រាំមិនពិពណ៌នាពុំបានដែរ ព្រោះតែសម្រស់ដ៏បំព្រងរបស់នាង ប្រៀបបីដូចដួងច័ន្ទរះបំភ្លឺវេហាស៍ក្នុងភពងងឹត ភ្នែកនាងល្អអ្វីម្ល៉េះ ! ភ្លឺថ្លាស្រទន់ត្រជាក់ដូចទឹកអម្រឹត





ពេលជិតដាមដោយតំណក់ទឹកភ្នែកដូច្នេះ ទឹកភ្នែកដូចគ្រាប់ពេជ្រ រំលេចកែវភ្នែកស្រីអោយមានន័យ អណ្តែតត្រសែត ឃើញហើយត្រូវតែយន់ចិត្តគិតអាសូរ។ បបូរមាត់នាងក្រមុំដូចក្លែបក្រូច ក្រហមព្រឿងៗដោយធម្មជាតិតាក់តែង មើលទៅរោមភ្នែកងច្រាងដូចគេពត់ សាច់សក្បុសរលោងស្រិលគួរអោយចង់ផ្តេកផ្តិត រាងរៅមូលក្លំមិនតូចមិនធំ គឺជាសម្រស់ដែលពិបាកនឹងរកអ្នកប្រៀបផ្ទឹមបាន។ មនោដាក់នង្គ័លចុះពីលើស្មា ហើយបញ្ចោក់ប្រាប់សង្សារដោយស្នាមញញឹមស្រាល :

-បានអីនឹងដឹង ! បើអូនឈរភ្លឹកមិនដឹងជាបណ្តែតអារម្មណ៍ទៅដល់ណាហើយទេ !

ស្រស់ស្រីឆ្លើយតបវិញដោយទឹកមុខស្ងប់ស្ងៀមដដែល :

-អោយអូនសុំទោស ! អូនពិបាកចិត្តពេក ក៏ចេះតែឈរបណ្តែតអារម្មណ៍រហូតភ្លេចខ្លួនមិនដឹងបងមកអ៊ីចឹងទៅ...

-អូនពិបាកចិត្ត !...? តើអូនមានរឿងអីទៅ ?

មនោសួរដោយសង្កត់សំលេង បើកភ្នែកធំៗបង្ហាញពីការភ្ញាក់ផ្អើល ។ ចំនែកនាងក្រមុំចោលភ្នែកមើលសង្សារបន្តិច ក៏គ្រលៀសចក្ខុឃើតៗចេញវិញសំលឹងទៅឆ្ងាយ ហាក់កំពុងគិតទៅដល់រឿងអ្វីមួយ រួចទើបខំខ្ជាក់សំដី តបមកបុរសវិញដោយវាចាមួយៗ :

-បងក៏ដឹងដែរថា ឪពុកអូនដែលបានទៅបំពេញបេសកកម្មនៅឯជាយដែនកាលពីឆ្នាំ ១៩៨៣ មកទល់ឥឡូវបាត់ដំណឹងសូន្យឈឹងមិនដឹងជាគាត់រស់នៅឯណាក៏មានសុខនិងទុក្ខយ៉ាងណានោះទេ... តែកាលពី ម្សិលមិញនេះ លឺដំណឹងថា កាលនោះគាត់បានធ្វើជាទាហានយាមព្រំដែននៅប៉ោយប៉ែត ហើយឥឡូវនេះគាត់ត្រូវបានគេផ្លាស់អោយ មកធ្វើការនៅភ្នំពេញវិញហើយ....

-អូនលឺដំណឹងនេះមកពីណា ? វាជាដំណឹងល្អទេតើ ! ម្តេចក៏អូនបែរជាពិបាកចិត្តទៅវិញ ? រំដួលលឺសំនួរម្ចាស់ចិត្តដូចនេះ នាងងាកមកមើលមុខសង្សារបន្តិច រួចក៏ឈ្ងោកបែរមុខចេញ សំលឹងមើលទៅទឹករលកដែលកំពុងរលេញរមេញតាមកំលាំងវាយោ ហាក់បីដូចជាចិត្តស្រីដែលកំពុងខ្វាយខ្វល់ពីរឿងជីវិត រួចនាងក៏បង្ហើបមុខថ្នមៗបញ្ចេញនូវ សំនៀងឆ្លើយតបទៅវិញ :

-បងដឹងទេ ? មីងពតដែលនៅភូមិជាប់យើងនេះ គាត់មកប្រាប់ម៉ែ... រឿងនេះល្អណាស់សំរាប់ខ្ញុំ សំរាប់ម៉ែ សំរាប់កូនកំព្រា សំរាប់អ្នកដែលព្រាត់ប្រាសឪពុក សំរាប់អ្នកដែលខ្វះភាពកក់ក្ដៅខ្វះការថ្នាក់ថ្នមលួង លោមពីឪពុក... បងដឹងហើយដប់ឆ្នាំមកនេះ ខ្ញុំរស់នៅម៉ង់ៗតែពីរនាក់ម្តាយនិងកូន ទ្រាំអត់ទ្រាំឃ្លាន... ស៊ូខំមាត់ជំនះនឹងជីវិតមិនហ៊ានថ្ងូរមួយម៉ាត់... លុះលឺដំណឹងពីឪពុកខ្ញុំសប្បាយចិត្តណាស់សប្បាយលើសអ្វីៗទាំងអស់... គឺសប្បាយនឹងបានឃើញមុខពុកសារជាថ្មីសប្បាយនឹងបានជ្រកក្រោមម្លប់ព្រហ្មវិហារធម៌... សប្បាយនឹងដៃលោកពុកទាំងទ្វេដែលតែងអង្អែលក្បាលកូនដោយទន់ភ្លន់... ពិសេសនោះគឺ





សប្បាយនឹងបានដូរឈ្មោះពីកូនកំព្រាពីកូនគ្មានឪមកជាកូនដែលមានទាំងម្ដាយមានទាំងឪពុកគឺពិតជាមានសេចក្ដីសុខណាស់ ។ កូនគ្រប់រូបមិនចង់បានទេឈ្មោះថា កូនគ្មានឪគ្មានម៉ែ ឬឈ្មោះថាកូនកំព្រាកូនអនាថា....។ កូនណាក៏តែងតែចង់បាននូវភាពកក់ក្ដៅការសន្ដោសប្រោសប្រណីពីម្ដាយពីឪពុកដូចៗតែគ្នាដែរ... បើមានម៉ែអត់ឪក៏ពិបាក ហើយបើមានឪអត់ម៉ែក៏កាន់តែពិបាកណាស់ទៅទៀត.... រំដួលឈប់បង្អង់បន្ដិច ដើម្បីសំរួលដង្ហើមនិងជូតទឹកភ្នែក ដែលរមៀលធ្លាក់ពីរបីតំនក់លើផែនថ្ពាល់ពណ៌ស៊ីជម្ពូ ។ ទឹកភ្នែកនេះជាទឹកភ្នែកដែលផុសចេញពីទឹកចិត្តរបស់កូនដែលបែកពីឪពុកយូរឆ្នាំ ។ បន្ដិចមករំដួលក៏ងាកមករកសង្សារដោយបង្ហូរសំលេងស្អកៗ :

-បងប្រហែលជាមិនដឹងទេ ?... អ្វីដែលធ្វើអោយអូនពិបាកចិត្តនោះគឺមិនមែនរឿងនេះទេ តែវាជារឿងស្នេហារបស់យើងទៅវិញតើ !... មិនមែនអូនឈប់ស្រលាញ់បងឬម៉ែអូនគាត់បំបែកនោះទេ... តែវេលានេះ ខណៈនេះវានឹងកន្លងទៅដោយនាំយកទាំងរូបអូនទៅជាមួយដែរ... បន្ដិចទៀតយើងនឹងបែកគ្នា... យើងនឹងខានឃើញមុខគ្នាទៀតហើយ... មិនដឹងពេលណា ថ្ងៃណា ខែណា ឬឆ្នាំណានោះទេ ដែលយើងបានជួបគ្នាវិញនោះ... ពេលនេះអូនមិនខុសអ្វីពីនាងទាវ ដែលត្រូវព្រាត់ពីទុំដោយសារតែចំនងគ្រួសារនោះឡើយ...

ឮសំដីសង្សារបរិយាយសេចក្ដីដូចនេះ មនោធ្លាក់ទឹកមុខស្រងូតបង្អើបជំហានមកជិតរំដួលរួចចាប់ដៃនាង មកកាន់ដោយបង្ហើរសំដីបែបភ្ញាក់ផ្អើល :

-អូននិយាយនេះបានន័យថាម៉េច ?... អូនត្រូវបែកពីបង... តើអូនទៅណា ? បើអូនមិនឈប់ស្រលាញ់បង... ម៉ែអូនក៏មិនបំបែក តើអ្វីដែលធ្វើអោយអូនឃ្លាតឆ្ងាយពីបង ? ប្រាប់មក ! ប្រាប់បងមក !...

មនោផ្ទួនសំដី រំដួលដកដៃយឺតៗចេញពីដៃសង្សារ ហើយងាកមកកាន់បង្កាន់ដៃស្ពាន ដោយចោលភ្នែកសំលឹងទៅឆ្ងាយរួចក៏បង្ហើបមាត់បញ្ចេញវាចា :

-មីងពតមកម្សិលមិញ បានប្រាប់ដំនឹងពីរឿងពុកនៅធ្វើការឯភ្នំពេញដល់ម៉ែ... ម៉ែអរណាស់ គាត់អោយខ្ញុំទៅភ្នំពេញជាមួយមីងពត ដើម្បីទៅរកពុក តែមិនដឹងថារកឃើញឬមិនឃើញទេ ព្រោះមីងពតមិនចាំអាស័យដ្ឋាន គាត់គ្រាន់តែដឹងថាពុកធ្វើការក្នុងក្រសួងការពារជាតិ ដូចនេះខ្ញុំត្រូវទៅយូរថ្ងៃ យូរខែមិនដឹងថ្ងៃណាបានជួបគាត់ ហើយវិលត្រលប់មកវិញទេ... ម្យ៉ាងទៀត បើបានជួបហើយយើងក៏កាន់តែឃ្លាតចាកពីគ្នាទៅទៀត ព្រោះថាម៉ែនឹងផ្លាស់ផ្ទះទៅនៅជាមួយពុកមិនខាន... រឿងមួយទៀតដែលធ្វើអោយខ្ញុំខ្វល់ខ្វាយមួយកំរិតដែរនោះ គឺខ្ញុំមិនដែលស្គាល់ភ្នំពេញទេ ហើយក៏កាន់តែមិនទុកចិត្តមីងពតទៅទៀត ដោយសុខៗស្រាប់តែគាត់មកប្រាប់ម៉ែពីរឿងពុកទាំងគាត់មិនសូវរាប់រកគ្រួសារអូនផងនោះ ។

-អូនអើយ !... ពេលនេះកម្មបានមកកាត់ផ្តាច់ចំនងស្នេហ៍យើងហើយ... សប្បាយហើយក៏ទុក្ខ ទុក្ខហើយសប្បាយ ជួបហើយក៏ព្រាត់... ព្រាត់ហើយថែមប្រាសទៀត... វាលវដ្តសង្សារបានកំនត់យ៉ាងច្បាស់ *"កើត ចាស់*





*ឈឺ ស្លាប់"* ម្តងទុក្ខម្តងសប្បាយ ម្តងជួបម្តងព្រាត់ផ្លាស់ប្តូរគ្នាទៅមក ទៅតាមចរន្តជីវិតរបស់មនុស្សម្នាក់ៗ...

មនោនិយាយទាំងអួលដើមក ភ្នែកសំលឹងមកមើលស្រស់ស្រីដែលកែវភ្នែកនាងមានសំនើមតិចៗ :

-អូនបែកមួយថ្ងៃដូចបែកមួយឆ្នាំ... មួយថ្ងៃដូចមួយសតវត្ស... មួយថ្ងៃដូចមួយជីវិត... ចុះទំរាំតែច្រើនថ្ងៃច្រើនខែ ហើយអាចបែករហូតទៀត តើអោយបងគិតយ៉ាងណាទៅ ?... ស្នេហាទើបតែចាប់ពន្លកឡើងក៏ស្រាប់តែមានឧបសគ្គមករារាំង បង្ខាំងមិនអោយពន្លកស្នេហ៍រីកដុះដាលត្រសុំត្រសាយទៅតាមសំទុះចិត្តដែលខំស្រលាញ់...... សំដីអូនប៉ុន្មានឃ្លាខាងលើនេះ បានធ្វើអោយបងស្លាប់ចិត្តទាំងរស់ បេះដូងបងដែលកំពុងពុះកញ្ជ្រោលដោយភ្លើងស្នេហ៍ក៏ត្រូវរលត់សូន្យឈឹងដោយទឹកសំដីប៉ុន្មានម៉ាត់នេះដែរ... តែណ្ហើយអូនអើយ ! ដើម្បីអូនបានជួបឪពុក ដើម្បីអូនបានជួបជុំគ្រួសារ... ដើម្បីអូននិងម្តាយមានទីពំនាក់ និងដើម្បីអោយអូនបានរស់នៅ ក្រោមម្លប់ដ៏ត្រជាក់នៃព្រហ្មវិហារធម៌របស់លោកទាំងពីរ សូមអូនទៅចុះ... ទៅអោយបានសុខ ហើយសូមអោយអូនបានជួបលោកឪពុកឆាប់ៗចុះ ព្រោះកូនណាក៏ដូចជាកូនណាដែរ មិនចង់រស់នៅកំព្រាបែកម៉ែបែកឪនោះទេ ទោះបើគេរស់នៅក្នុងខ្ទមកំសត់ ឬតាមសំញ៉ាបផ្ទះគេក៏ដោយ បើបានរស់នៅជិតម៉ែជិតឪ កូនគ្រប់រូបតែងមានអារម្មណ៍ថា កក់ក្តៅណាស់ បាត់ភ័យ បាត់ខ្លាច ដូចរស់នៅក្នុងភូមិគ្រឹះដ៏ធំ

អស្ចារ្យ ។ អូនទៅចុះ !.... កុំគិតពីបងអី.... បើយើងពិតជាគូនឹងគ្នាមែននោះ ក៏គង់នឹងមិនព្រាត់គ្នារហូតដែរ.... ថ្ងៃណាមួយ ពេលណាមួយ យើងនឹងជួបគ្នាវិញមិនខាន។

រំដួលកាលបើឮសារស័ព្ទសម្ដីរបស់សង្សារបណ្ដូលចិត្តដូចនេះ នាងរំដួលចិត្តយ៉ាងខ្លាំង ទឹកភ្នែកក៏ដណ្ដើមគ្នារមៀលធ្លាក់ចុះតាមជ្រលងផែនថ្ពាល់ :

-បង !... សូមបងចាំចុះ ផ្ការំដួលមួយទងនេះ នឹងរីកតែក្នុងបេះដូងបងម្នាក់ប៉ុណ្ណោះ... ផ្ការំដួលនេះបើគ្មានបងជាទឹកសន្សើម សម្រាប់ប្រស់ព្រំនោះទេវានឹងមិនអាចមានជីវិតរីកបង្ហាញសម្រស់ធម្មជាតិទៅទៀតបានឡើយ។ ថ្វីបើរំដួលអូនត្រូវដូរដី ដូរមាតុភូមិក៏ដោយ ក៏រំដួលអូននេះនៅតែនឹករលឹក... នៅតែគិតឃើញពីគុណបំណាច់ ពីអនុស្សាវរីយ៍ដែលធ្លាប់សាង ធ្លាប់បានបង្កើតទុកមក មិនអោយឃ្លាតចាក ឬភ្លេចភ្លាំងពីសម្បជញ្ញៈឡើយ ។ ចំនែកបងនៅទីនេះ សូមបងរស់នៅអោយបានសេចក្ដីសុខ... ស្អែកអូនទៅហើយ... ទៅដោយពាំនាំសម្ដីបងទុកក្នុងចិត្តជានិច្ច...

ព្រះសុរិយាបានមកជួបផែនពសុធាតាមការណាត់ ហើយផ្សព្វផ្សាយរស្មីក្រហមឆ្អៅបំភ្លឺដល់មនុស្សសត្វផងទាំងឡាយ។ ព្រលឹមស្រាងៗ រ៉ឺម៉កឌុប





មួយបានពន្លត់ម៉ាស៊ីនឈប់ទ្រឹងនៅមុខផ្ទះរំដួល ដែលមានមនុស្សអ៊ូអរឈរចាំជូនដំណើរ។ ភ្លាមនោះពេលឃើញរ៉ឺម៉កមកដល់ ម្ដាយរំដួលក៏ឧទាន :

-បានហើយរំដួលកូនឈប់យំទៅ ! រ៉ឺម៉កមកដល់ហើយ... ទៅចុះ ! ម៉ែនៅទីនេះមិនអីទេ សូមកូនទៅអោយបានសុខហើយឆាប់រកឪពុកកូនឃើញ...

ស្ត្រីចំនាស់ជាម្ដាយដែលកំពុងឈរអោបកូន ហើយអង្អែលក្បាលនាងថ្នមៗដោយក្ដីសន្ដោសមេត្តាក៏បង្ហើបខ្លួនរំដួលចេញពីដើមទ្រូងដ៏សែនកក់ក្ដៅ រួចស្រស់កញ្ញាក៏ដើរថយក្រោយយឺតៗក្នុងអាការៈហេងហាង។ ព្រមជាមួយគ្នានោះមីងពត ក៏ដើរមកដឹកដៃនាងអោយដើរតាមដូចកូនក្មេង។ ឃើញដូចនោះម្ដាយនាងក៏ស្រែកផ្ដាំមីងពតជាលើកចុងក្រោយ :

-ពតអើយ ! មើលៗវាផង អ៊ំទុកចិត្តលើក្មួយហើយ។

-ចាំ ! កុំព្រួយអ៊ំ ទុកចិត្តចុះ។

មីងពតនិយាយដោយងាកមករកម្ដាយរំដួល បង្ហើបរង្វះមាត់ពណ៌ក្រហមទុំ បញ្ចេញធ្មេញមាសមួយពណ៌លឿងឆ្អៅដែលបង្កប់ជាមួយធ្មេញដទៃទៀត។ មីងពតមានអាយុប្រហែល៣៥ឆ្នាំ មាឌធាត់បន្តិច ចូលចិត្តស្លៀកពាក់ឆើតឆាយនិងផាត់ក្រែមម្សៅក្រាស់ៗលើសស្រីក្រមុំក្នុងភូមិទៅទៀត។

ចាំបាច់ទៅមើលឯណាឆ្ងាយ ! សូម្បីតែនាងក្រមុំរំដួល ដែលឡើងទៅអង្គុយលើរ៉ឺម៉កឯនោះ ក៏ផាត់ក្រែមម្សៅចាញ់មីងពតដែរ ។ ពេលអ្នកដំណើរឡើងជិះលើរ៉ឺម៉កអស់ តៃកុងម៉ូតូក៏បញ្ឆេះម៉ាស៊ីនទ្រឹលៗ ហើយក៏ឌុបអ្នកដំណើរ

ចេញទៅ ។..... រំដួលចោលភ្នែកសំលឹងមើលផ្ទះកំសត់ដោយមិនចង់ឃ្លាត នាងលើកដៃវាចុះឡើងដាក់ម្តាយ សង្សារ និងញាតិមិត្តទាំងអាល័យ.....

ម៉ោងប្រាំបីព្រឹក រ៉ឺម៉កម៉ូតូបានបញ្ជិះអ្នកដំនើរទៅដល់ទីរួមខេត្តកំពង់-ចាម ហើយក៏ផ្ទេរបន្តទៅឱ្យតាក់ស៊ីដើម្បីដឹកអ្នកដំនើរទៅកាន់ទីក្រុងភ្នំពេញ។ កាលបើតាក់ស៊ីផ្ទុកអ្នកដំនើរពេញហើយនោះ តៃកុងក៏ចាប់ផ្តើមចាក់សោរបញ្ឆេះយានអោយកន្ទ្រាក់ដង្ហើមលឺសូរទ្រឹល១ ហាក់ដាស់សត្វចតុបាទដ៏ធំមួយអោយភ្ញាក់ពីដំនេក។ តៃកុងជាន់ហ្គែរោទិ៍សំលេងបន្តិចទើបរថយន្តឈ្មួលចាប់គ្រលែងខ្លួនបោលចេញពីចំនតរថយន្តផ្សារធំកំពង់ចាម ឆ្ពោះទៅកាន់រាជធានីភ្នំពេញ បេះដូងនៃព្រះរាជាណាចក្រកម្ពុជា។ រថយន្តចេះតែលឿនលយទៅមុខឯទំនុកច្រៀងរបស់តារាចំរៀងល្បី១នាទសវត្សទី៦០ ក៏បានផុសអណ្តែតត្រសែតមកប៉ះសោតិន្ទ្រីយារម្មណ៏របស់អ្នកធ្វើដំនើរមួយបទហើយមួយបទទៀត។ មកដល់ត្រឹមនេះ សូរសំលេងខ្ទើយ១នៃអធិរាជសំលេងមាស ស៊ិន ស៊ីសាមុត ក៏ចាប់ផ្តើមបង្ហើរឡើងចេញពីម៉ាញេរថយន្តយ៉ាងល្វេងល្វើយ "ភ្នំប្រុសភ្នំស្រីដីកំពង់-ចាមប្រលាក់ជាប់ស្នាមដាមជីវិតខ្ញុំ....." សូរសំនៀងមួយបទនេះ កាលបើបានរសាត់មកប៉ះសោតាអ្នកណាហើយ ទោះបីគេមិនមានវិបត្តិស្នេហ៍ មិនមានការព្រាត់ ប្រាសពីសង្សារ គ្មានការឃ្លាតចាកពីស្រុកកំនើត... ក៏គង់គេនឹងមានអារម្មណ៏ស្តាយស្រណោះ អាលោះអាល័យឬសង្វេគចិត្តនឹកអាណិតទៅដល់អ្នកជួបវិបត្តិដូចវាចាថ្លាថ្លៃងទួញទុក្ខរបស់អធិរាជសំលេងមាសជាក់ជាពុំខានឡើយ។





ឱហ្ន៎ !..... ចុះទំរាំនាងរំដួល ដែលជាអ្នកជួបនូវគំនរទុក្ខទាំងនេះ នឹងមានអារម្មណ៏យ៉ាងណា ? មើលចុះ ! សូម្បីតែនាងខំទប់ទឹកភ្នែកយ៉ាងណាក្តី ក៏តំនក់ទឹកភ្នែកតូច១នៅតែរមៀលធ្លាក់ ប្រដេញគ្នាលើផែនថ្ពាល់នាង អោយខាងតែបានដែរ ។ រំដួលស្ទើរតែមិនចង់ឈានជើងចេញពីភូមិកំនើតឡើយ តែដោយសេចក្តីនឹករលឹកឪពុក សេចក្តីកតញ្ញូតាធម៌ ការចង់ស្គាល់ទីក្រុងភ្នំពេញ និងពាក្យបញ្ចុះបញ្ចូលដ៏ប៉ិនប្រសប់របស់មីងពត ទើបនាងដាច់ចិត្តមកដោយខានពុំបាន ។ តាំងពីតូចម្ល៉េះ ទីក្រុងភ្នំពេញឋិតក្នុងក្តីស្រមៃរបស់នាងជានិច្ច ។ គ្រប់ពេលអោយតែមាននរណាម្នាក់និយាយពីភ្នំពេញ គឺនាងចូលចិត្តស្តាប់ណាស់ ពេលខ្លះស្តាប់ឡើងច្រហមាត់ ហើយពេលខ្លះទៀត ស្តាប់ឡើងភ្លេចបាយ ភ្លេចទឹកទៅហើយ ព្រោះនាងចង់ដឹងថា ភ្នំពេញស្រស់ស្អាតយ៉ាងណា ? ភ្នំពេញជាឋានសួគ៌មែនឬ ?... បានជាឃើញតែគេល្បី គេសរសើរ ហើយនាំគ្នាសំរុកមកភ្នំពេញគ្រប់១គ្នានោះ ? ចំងល់ទាំងអស់នេះហើយ ដែលធ្វើអោយនាងគិតមមៃស្រមៃរក និងទន្ទឹងរង់ចាំវាសនាថា ថ្ងៃណាមួយនាងនឹងមកអោយឃើញទីក្រុងភ្នំពេញម្តងព្រោះ ***លឺគេនិយាយ១០ដង មិនស្មើនឹងបានឃើញម្តងឡើយ*** ។

ដោយរថយន្តបើកកាត់ទ្រូងផ្លូវដែលអមទៅដោយព្រៃព្រឹក្សា និងដំណាំចំការឈើហូបផ្លែរបស់ប្រជាកសិករ ទើបគេលឺសូរតែសំលេងសត្វបក្សាបក្សីយំគួរអោយស្រណោះលន្លង់លន្លោច។ ផុតពីដំនាំចំការនានាក៏លេចឡើង

នូវវាលស្រែពណ៌ខៀវស្រងាត់ លាតសន្ធឹងល្វឹងល្វើយជាក្រឡាចត្រង្គប្រៀបបាននឹងកំរាលព្រំពណ៌ខៀវខ្ចី លាយឡំជាមួយផ្កាអញ្ចាញពណ៌លឿងដូចមាសឆ្អិនហាក់ផ្តិតជាប់នឹងកំរាលព្រំបៃតងនោះ។ បើគេក្រលេកមើលទៅឆ្ងាយគេនឹងប្រទះឃើញបក្សីជើងវែងទាំងហ្វូងៗ កំពុងហើរវេរាក្រឡឹងចុះឡើងលើភ្លឺស្រែដើម្បីចាំឆ្នក់ចឹកត្រីក្នុងចន្លោះគុម្ពស្រូវធ្វើជាចំនី។ ដើមត្នោតខ្ពស់ៗខ្មៅស្រិលរាប់រយដើមដុះជាប់យ៉ាងជង្រ្គឹងតាមទំនប់ភ្លឺស្រែ ហាក់បីដូចជាឆ្មាំដ៏ក្លាហានកំពុងឈរសំញែងខ្លួនការពារមាតុប្រទេសនិងផលដំនាំរបស់ប្រជាកសិករ។ ទេសភាពទាំងអស់នេះមាននាទីជាអង្រឹងយោលយោគមនោរម្មណ៍របស់អ្នកដំនើរអោយស្រងេះស្រងោចនឹកមមៃទៅដល់ស្រុកកំនើត និងសង្សារបណ្តូលចិត្ត ដែលនឹងត្រូវឃ្លាតចាកឆ្ងាយ។

យូរៗម្តងរំដួលដកដង្ហើមធំ លឺសូរឃ្យូរៗបញ្ចេញនូវភាពតានតឹងក្នុងអារម្មណ៍អោយផុសចេញឡើង។ ពេលនេះនាងស្រាប់តែមានកូនគំនិតមួយគិតថា "បើពុករបស់ខ្ញុំគាត់មករស់នៅភ្នំពេញ ហេតុអ្វីបានជាគាត់មិនមករកប្រពន្ធកូន ត្បិតអីភ្នំពេញនិងកំពង់ចាមនៅមិនឆ្ងាយពីគ្នាប៉ុន្មានឯណា ?" គិតបានប៉ុណ្ណេះ នាងក៏ដកដង្ហើមធំទៀតដោយឆ្លៀតបែរមុខទៅមើលទេសភាពតាមកញ្ចក់រថយន្តធ្វើព្រងើយ លែងគិតលែងខ្វល់ទៀត។ ចំនែកមីងពតទឹកមុខគាត់ញញឹមស្រស់ស្រាយ ហាក់មានសង្ឃឹមនិងមានបំនងចង់ធ្វើអ្វីមួយយ៉ាងលាក់លៀម។



### វគ្គទី២

# លង់ខ្លួននៅភ្នំពេញ

ថិរវេលាថ្មើរនេះ ទ្រនិចនាឡិកាចង្អុលម៉ោងដប់មួយថ្ងៃត្រង់ទៅហើយ..... រថយន្តបានបន្ថយល្បឿនយឺតៗហើយឈប់ង៉ក់កណ្តាលបេនឡានផ្សារធំថ្មី។ មនុស្សម្នាអ៊ូអរ ម៉ូតូឌុប ស៊ីក្លូ ឡានឈ្នួលច្រវេតច្រវាត់ចុះឡើងលើដងវិថីតាមចន្លោះអគារខ្ពស់ៗទំនើបៗ ដែលពីមុនមករំដួលមិនធ្លាប់ឃើញសោះក្នុងជីវិតនាង។ នាងជាអ្នកស្រែចូលក្រុងសុទ្ធសាធ ខួរក្បាលនាងវិលក្បុងអស់ហើយ អរផងភ័យផងមិនដឹងជាទៅខាងណា។ ពេលនោះ គេឮសូរទ្រហឹងអឺងកងនៃក្មេងលក់កាសែត ទស្សនាវដ្តីលាយឡំនឹងសម្លេងក្មេងទូលថាសស្ករគ្រាប់ ស្ករកៅស៊ូ គ្រាប់ឪឡឹក គ្រាប់ល្ពៅ គ្រលីងឈូក ស៊ីឌី វីស៊ីឌី និងកាហ្សែតចម្រៀងល្បីៗចេញថ្មី ស្រែកពពាយនាយច្របូកច្របល់ជាមួយនឹងអ្នកលក់នំប៉័ងនិងក្មេងលក់ទឹកកក ទឹកអំពៅយួរទាំងថង់ៗរណោងរណោង ប្រជ្រៀតគ្នាដើរចុះដើរឡើងពេញចំណតរថយន្ត។ នៅពេលឃើញរថយន្តឈ្នួលឈប់ទ្រឹងកណ្តាលបេន ក្រុមអ្នករត់ម៉ូតូឌុបផ្អើលព្រួប្រជែងគ្នាមករោមឡានដែលកំពុងខ្វាក់អ្នកដំណើរចេញពីទម្ងន់បន្ទុករបស់វា។ សកម្មភាពនេះសឹងក្លាយជាប្រពៃណីរបស់អ្នករកស៊ីតាមចំណតរថយន្តទៅហើយ ថ្វីបើវាធ្វើអោយគ្មានសណ្តាប់ធ្នាប់របៀប

រៀបរយនិងប៉ះពាល់ទៅដល់សោភ័ណភាពទីក្រុងក៏ដោយ ។ ពេលនោះមីងពត ចុះពីរថយន្ត ហើយចាំដឹកដៃរំដួលដោយពោលពន្យល់ :

-កុំដើរផ្ដេសផ្ដាស ! ប្រយ័ត្នពួកអ្នករត់ម៉ូតូឌុបកញ្ឆក់ឥវ៉ាន់ទាញមុខទាញក្រោយ ជូនរហែកកាបូប ជូនធ្លាក់ឥវ៉ាន់បែក ឬបើយើងមើលមិនទាន់ត្រូវពួកវាបណ្ដាក់គ្នាពីម្នាក់ទៅម្នាក់យកឥវ៉ាន់ទៅបាត់... ត្រូវប្រយ័ត្នអោយមែនទែន !

រំដួលស្ដាប់សម្ដីមីងពតធ្វើភ្នែកឡិងឡង់ងាកមើលឆ្វេងស្ដាំ :

-ចាស ! មីង... តើយើងគិតទៅណាទៀត ?

មីងពតកាន់ដៃរំដួលដើរឆ្លងថ្នល់ :

-មក៏ ! ទៅហូបបាយសិនចាំគិតទៀត ។

ក្រោយពីកុម្ម៉ង់ម្ហូបរួច មីងពតនិងរំដួលក៏ទៅអង្គុយចាំហូបបាយលើកៅអីដែលគេរៀបចំដាក់ជុំវិញតុរួចជាស្រេច ។ ពេលម្ហូបបាយលើកមកដល់ មីងពតហូបបាយបណ្ដើរនិយាយបណ្ដើរ :

-ដូចរំដួលឯងដឹងស្រាប់ហើយ... មីងក៏គ្មានលុយ ឯងក៏ទ័ល ! ដូច្នេះទាល់តែជួយគ្នាទើបបាន បើមិនដូច្នោះតាមរកឪពុកឯងមិនឃើញទេ ត្បិតអីយើងគ្មានប្រាក់ ។

-អ៊ីចឹងមីងចង់អោយខ្ញុំធ្វើម៉េច ? (រំដួលសួរទាំងមុខស្លូត)

មីងពតសម្លឹងមើលខ្សែដៃដែលពាក់ជាប់នឹងកដៃរំដួល រួចនិយាយ :





-អឺ... នែ ! ខ្សែដៃឯងនោះ ទម្ងន់ប៉ុន្មានដែរ... ?

-ចាំ ! ប្រាំជី...

-អ៊ីចឹងល្អហើយ ! ឯងលក់ខ្សែដៃនេះសិនទៅដើម្បីជាទុនតាមរកឪពុកឯង ។

រំដួលដែលកំពុងកាន់ស្លាបព្រាលូកទៅដួសម្ហូបក៏ទុចង៉ក់ យកស្លាបព្រាមកដាក់លើចានបាយវិញ :

-មីង ! ចាំបាច់ត្រូវការលុយច្រើនណាស់ឬគ្រាន់តែរកពុកនោះ ? ហេតុអីក៏ដល់ថ្នាក់លក់ខ្សែដៃ ?

មីងពតដែលកំពុងទំពារផ្ងាច់ៗក៏ទំលាក់ស្លាបព្រាចុះ ហើយនិយាយទាំងម៉ូរហ្មង :

-ឯងស្មានថាភ្នំពេញតូចឬ ? រកឪពុកឯងម្នាក់ដូច ***រកម្ជុលក្នុងបាតសមុទ្រ*** អ៊ីចឹង ! ឯងត្រូវដឹងថានៅទីនេះមួយជំហានក៏លុយដែរ !

-ចុះក្រែងមីងប្រាប់ថា ពុកធ្វើការនៅក្រសួងការពារជាតិហ្ន៎ !

-អើ ! រឿងហ្នឹងមីកាភេម វាប្រាប់អញដែរហ្នឹង !... ឥឡូវលក់ខ្សែដៃហ្នឹងសិនទៅ ! ចាំទៅដេកផ្ទះកាភេមហើយអោយវាជូនទៅរក ។

ឮថាមីងពតដឹងដំណឹងតាមគេដែរ រំដួលធ្លាក់ថ្លើមក្ដុកស្ទើរស្រែកយំ :

-តែខ្សែដៃនេះជាកេររបស់យាយខ្ញុំ ! ពេលមកភ្នំពេញនេះទើបម៉ែយកមកពាក់អោយ... អ៊ីចឹងអោយខ្ញុំលក់ម្ដេចបាន !...

-មិនអីទេ ! ពេលយើងរកឪពុកឯងឃើញ ចាំទិញលោះវិញទៅ វាមានទៅស្អី !

-អីចឹងតាមតែមីងចុះ !... (រំដួលឆ្លើយយល់ព្រមទាំងមិនពេញចិត្ត) ។

........ ក្រោយពីបានលក់ខ្សែដៃបានលុយហើយ មីងពតក៏នាំរំដួលទៅជួលផ្ទះស្នាក់នៅ បណ្តោះអាសន្ននៅម្តុំបឹងកក់ ដែលផ្ទះជួលទាំងនោះ ជាផ្ទះរបស់មីងកំភេមមិត្តចាស់របស់គាត់ ។ មីងកំភេមគឺជាស្រ្តីម្នាក់ ដែលមានមាឌធាត់កន្តុល សក់រួញដូចអន្ទង់អាំង រង្វង់ភ្នែកធំៗឡើងខ្មៅក្រឹប ការពារទៅដោយរោមភ្នែក ងខ្មីតដូចកន្ទុយខ្ទួយ ។ ចំនែករោមចិញ្ចើម ត្រូវបានគូសវាសកែច្នៃឡើងកោងដូចឥន្ទធនូ ផ្ទៃមុខជាំក្រហម តែពេលផាត់ម្សៅពីលើទៅ បើមិនចាប់អារម្មណ៍ក៏មើលមិនដឹង បបូរមាត់ទាំងក្លែបក្រាស់ៗ ជិតដាមដោយក្រេមក្រហមក្រមៅ ។ រូបរាងរបស់គាត់បែបនេះ សមទៅនឹងចរិតវាយឫកបែបឆ្មើងសម្តីផ្អែមរលួយតែចិត្តខាងក្នុងមានពុតត្បុតកលល្បិចមួយម៉ឺនជំពូក ។ មីងកំភេមក៏មានស្រុកភូមិនៅជាមួយនាងរំដួលដែរ តែដោយមានបញ្ហាខ្លះៗជាមួយគ្រួសារអ្នកភូមិ គាត់ក៏មករស់នៅភ្នំពេញប្រកបរបរជួលផ្ទះ ដើម្បីងាយស្រួលប្រកបរបរទីពីរមួយទៀត ដែលគាត់ធ្លាប់បានបោកប្រាស់អ្នកភូមិច្រើនដងមកហើយលើមុខរបរសម្ងាត់នេះ ។ មនុស្សបែបមីងកំភេមនេះជាមនុស្ស *ក្តៅស៊ីរាក់*





*ត្រជាក់ស៊ីជ្រៅ* ដោយហេតុថា ទឹកឃ្មុំផ្អែមម្តេចនៅមានពិស ផ្កាកុលាបដ៏ស្រស់ស្អាតជាទីចាប់អារម្មណ៍ នៃភមរាទាំងឡាយក៏គង់នៅមានបន្លា ។ ចំនែកផ្លែល្វាពណ៌រលោងភ្លឺថ្លា ក៏មិនប្រាកដថាខាងក្នុងគ្មានដង្កូវមមង់គួរអោយអសោចន៍នោះដែរ ។ យ៉ាងណាមិញ ចរិតមនុស្ស គំនិតមនុស្សក៏មិនខុសគ្នាដែរ យើងមិនអាចឃើញគេមួយភ្លែតអាចវាយតម្លៃថា អ្នកនេះល្អ អ្នកនោះអាក្រក់បានទេហើយក៏កាន់តែមិនអាចដឹងទៀតហើយ បើគ្រាន់តែមើលចរិតនិងកាយវិការខាងក្រៅនោះ ។

កាលបើបានឈានជើង ចូលមកស្នាក់នៅក្នុងផ្ទះមីងកំភេមកាលណា រំដួលមានអារម្មណ៍ភ័យប្លែកទៅនឹងទិដ្ឋភាពនានា គ្រប់បន្ទប់គ្រប់ល្វែងនិងគ្រប់សកម្មភាពនានា របស់មនុស្សដែលជួលនៅយូរ និងអ្នកដែលមកនៅត្រឹមតែមួយយប់ ឬខ្លះមិនដល់មួយម៉ោងផង ពិសេសបុរសៗ ដែលជូនទៅក៏មាននាំស្រីមក ហើយជូនកាលទៀតក៏មានតែម្នាក់ឯង ។......

សេចក្តីមន្ទិលរបស់មាណវីស្រុកស្រែ ប្រហែលជានឹងត្រូវលេចចេញជារូបរាងហើយ... នៅរសៀលថ្ងៃនេះ មីងពតកំពុងដើរសំដៅទៅបន្ទប់មីងកំភេមៈ

-តុក !... តុក !... តុក !... កាភេម ! កាភេម ! បើកទ្វារអោយយើងចូលតិច !

ឮសម្លេងមីងពត ម្ចាស់បន្ទប់បើកទ្វារថ្នមៗខ្លាចឮសម្លេង...។ កាលបើទ្វារបើកហើយ មីងពតក៏រំលៀកខ្លួនចូលទៅដោយបង្អើបសម្លេងតិចៗសឹង

មិនឮសូរ :

-ម៉េចហើយ ! តម្លៃដែលយើងនិយាយគ្នានោះ... យល់ព្រមទេ ? ឮសំណួរនេះ មីងកំភេមទាញដៃមីងពតឱ្យទម្លាក់បង្គុយលើគ្រែពូកទន់ល្មើយ :

-អូ ! រឿងហ្នឹងហ្ន៎ ?... តម្លៃខ្លួននាងក្ដាមស្រែម្នាក់ហ្នឹង ខ្ញុំឱ្យ ២០០ដុល្លា... ម៉េចដែរ?

-ថោកម៉េស ! ស្អាតប៉ុណ្ណឹងហើយនៅអោយថោកទៀត !... មុខដូចកូនកាត់សាច់សអោយខ្ចី បុរសណាឃើញក៏ទ្រាំមិនបានដែរ... ឥឡូវខ្ញុំសុំ ៣០០ ដុល្លាចុះ !

សញ្ជឹងបន្តិច មីងកំភេមញញឹមហើយតប :

-អ៊ីចេសចុះ ! ខ្ញុំសុំចុះ ៥០ ទៀត ព្រោះត្រូវហុចអោយប៉ូលីសតិច ! ហុចអោយអាដៃដល់តិច ! វាអស់បាត់ទៅហើយ ម្យ៉ាងឥឡូវលក់មិនបានថ្លៃប៉ុន្មានទេ ព្រោះក្ដាមស្រែអស់នេះវាសម្បូរណាស់ ភ្លើៗ ! ខ្ញាំតែតិចបានភ្លាម។

-តស់ ! ២៥០ ក៏ ២៥០ ទៅ ! អោយតែលក់ជាមួយកាភេមឯងមិនដែលបានថ្លៃទេ។ នេះដោយកុំតែកាភេមឯងស្គាល់កន្ទុកកន្ទ្បែតច្បាស់ កុំអីរត់ការខ្លួនឯងបាត់ មិនខ្ចីពឹងទេ !

មីងកំភេមយកដៃទះស្មាមីងពតតិចៗធ្វើជាលួង :

-ទៅ !.. ចុះខ្ញុំមិនយកក្ដាមស្រែនេះមកស៊ីរហូតឯណា គង់តែបានកាពតឯងយកទៅណោះណោះទៀតតើ !





ក្រោយពីពិភាក្សាគ្នារួច នៅថ្ងៃបន្ទាប់ស្ត្រីទាំងពីរក៏នាំរំដួល មកចូលសណ្ឋាគារដ៏ទំនើបមួយឈ្មោះ **ហ្គូលដិនហូថែល** *(GOLDEN HOTEL)* ដើម្បីលក់នាងអោយជនជាតិកូរ៉េម្នាក់ ក្នុងតម្លៃ ៨០០ ដុល្លា។ ឈានជើងចូលដល់សណ្ឋាគារពេលណា រំដួលមានអារម្មណ៍រំភើបត្រជាក់ ហើយប្រែជាចង់រងារដោយសារឥទ្ធិពលនៃម៉ាស៊ីនត្រជាក់ដ៏ទំនើបៗ ។ រួមជាមួយគ្នានោះ នាងក៏ប្លែកភ្នែកនឹងគ្រឿងបរិក្ខារល្អវិចិត្រ រំលេចដោយក្បាច់រចនាតាមម៉ូតបរទេសផងដែរ ។ អ្នកទាំងបីបន្តដំណើររហូតឡើងទៅដល់ជាន់ទីប្រាំ រួចក៏បត់ឆ្វេងតម្រង់ទៅរកបន្ទប់លេខ ៥១៥ តាមការគូសបង្ហាញរបស់អ្នកទទួលភ្ញៀវ ។ កាលបើទ្វារបន្ទប់របើកភ្លាម ភ្លើងអំពូលពណ៌លឿងទុំក៏ជះពន្លឺមកលើរូបពួកគេ ហើយក៏លេចចេញនូវគ្រែពូក ខ្នល់ខ្មើយរៀបចំយ៉ាងមានរបៀប នៅរ៉ែកម្ខាងនៃបន្ទប់ ។ ទូសម្អាងភ្លឺរលោងមួយឈរជង្រ្គឹងអែបក្បែរនោះ ក្លិនក្រអូបភាយនៃទឹកអប់ដែលគេបាញ់ផ្អប់ក្នុងបន្ទប់ ក៏ជះក្លិន យ៉ាងប្រហើរមកប៉ះនាសាស្ត្រីទាំងបី ។ មីងកំភេមទាញកៅអីមកអង្គុយមុខទូសម្អាង ហើយចាប់និយាយទៅកាន់រំដួល ស្របពេលដែលនាង និងមីងពតដាក់បង្គុយចុះដែរ :

-មីងនាំឯងមកនេះ គឺនាំមកអោយធ្វើជាអ្នកម៉ាស្សាជូនភ្ញៀវដែលគេមកស្នាក់នៅក្នុងសណ្ឋាគារនេះ ម្ចាស់សណ្ឋាគារគេព្រមអោយឯងធ្វើការហើយ ! នេះក៏ព្រោះមីងស្គាល់គេដែរ ខំធ្វើការទៅ !... ម៉ាស្សាតែមួយភ្លែត បានលុយ

ភ្លាម ហើយបានច្រើនទៀត ពេលបានលុយរំដួលឯងនឹងងាយស្រួលក្នុងការតាមរកឪពុកហើយ ចាំមីងជូនទៅកុំបារម្ភពីរឿងនេះ ។

រំដួលធ្វើមុខ ឡិងឡង់ត្បិតមិនយល់ពីការងាររួចនាងបង្ហើបមាត់សួរបញ្ចេញធ្មេញសថ្លា :

-ម៉ាស្សា... យ៉ាងម៉េចទៅ ?... ខ្ញុំមិនធ្លាប់ធ្វើទេ !...

មីងកំភេមក្រោកពីកៅអី យកដៃក្បៀកស្មារំដួលបង្ហាញភាពស្និទ្ធស្នាលដើម្បីលួងចិត្ត :

-កុំព្រួយអី ! ការងារនេះមិនពិបាកទេ គឺឯងគ្រាន់តែច្របាច់ដៃច្របាច់ជើងធ្វើសរសៃអោយភ្ញៀវទៅបានហើយ !

ឃើញរំដួលរារែកចិត្ត មីងពតទះជង្គង់នាងតិចៗបង្ហាញនូវការលួងលោម :

-ព្រមធ្វើទៅរំដួល ! មិនងាយមានឱកាសទេ អ្នកខ្លះចង់ធ្វើហើយមិនបានធ្វើទៀត ឯអ្នកខ្លះដល់ថ្នាក់យកលុយមកសូកគេហើយក៏នៅតែមិនបានធ្វើ ! ចុះឯង ?... ការងារមកដល់ដៃចំណីមកដល់មាត់ហើយមិនចង់ធ្វើទៀតហ្អី ?... !

ហេតុតែនាងល្ងង់ ទទួលបានការអប់រំតិចតួច គ្មានបទពិសោធន៍ក្នុងជីវិតរស់នៅ និងមិនយល់ពីល្បិចមនុស្សនៅក្នុងសង្គម ទើបធ្វើអោយស្ត្រីទាំងពីរងាយស្រួលបោកបញ្ឆោតណាស់ ។ ដោយជឿតាមសម្ដីគេ ក្រមុំស្រុកស្រែក៏យល់





ព្រមរង់ចាំធ្វើការងារម៉ាស្សា ក្នុងបន្ទប់នេះទាំងងឹតងងល់ ព្រោះអីនាងធ្លាប់តែដឹកគោទៅវាលស្រែអោយស៊ីស្មៅនិងថែទាំប៉ុណ្ណោះ ។ ពេលនោះមីងកំភេមអោយនាងផ្ដិតមេដៃលើក្រដាសមួយសន្លឹកប៉ុន្តែរំដួលមិនដឹងគេសរសេរ យ៉ាងម៉េចទេ ព្រោះនាងរៀនបានទាប ទោះខំអានផងប្រកបផងទាំងតតាក់តតុបយ៉ាងណាក៏នៅតែមិនយល់ន័យ :

-ក្រដាស់អីហ្នឹងមីង ? ខ្ញុំមើលមិនយល់ទេ !

ឮរំដួលថាអានមិនយល់មីងពតនិងមីងកំភេមនឹកអរព្រួច ព្រោះវាធ្វើអោយពួកគេកាន់តែងាយស្រួលបោកប្រាស់នាង :

-អើមិនអីទេ ! ( មីងពតនិយាយ) កាភេមវាមិនបោកឯងទេ ឆាប់ផ្ដិតមេដៃត្រង់នេះទៅ ! វាជាកិច្ចសន្យាធ្វើការតើ !

គ្រាន់តែឮថាកិច្ចសន្យាធ្វើការ រំដួលផ្ដិតមេដៃខ្វាច់ ដោយមិនចាំបាច់គិតពិចារណា ។ កាលបើស្នាមមេដៃបានលេចប្រាកដឡើងលើសន្លឹកក្រដាសហើយ ស្ត្រីទាំងពីរញញឹមខ្ជឹបហើយក៏ចុះមកក្រោមវិញ ដោយនិយាយប្រាប់រំដួលថា នឹងមកទទួលនាងរាល់ថ្ងៃ ពេលចេញពីធ្វើការពាក់កណ្ដាលអធ្រាត្រ ទំរាំនាងចំនាំផ្លូវទៅផ្ទះច្បាស់ ។ មីងពត និង មីងកំភេមចេញបានបន្តិច ក៏មានគេលើកផ្លែឈើ មានផ្លែប៉ោម ល្មុត និង មៀន មកអោយនាងទទួលទាន :

-នេះផ្លែឈើ ! ថៅកែអោយលើកមកអោយ !

-ចាំ ! អរគុណ... (រំដួលឆ្លើយទាំងរអាចិត្ត)

-ខ្ញុំទៅវិញហើយ ញ៉ាំតាមសម្រួលចុះ !

និយាយហើយ នារីបំរើដែលតុបតែងដោយឈុតសំលៀកបំពាក់សណ្ឋាគារដ៏ស្រស់ស្អាត ក៏ទាញទ្វារបិទនិងឆ្លៀតលួចមើលស្នាមញញឹមចុងមាត់របស់បុប្ផាជនបទទាំងនឹកសរសើរ និងសោកស្តាយជំនួស "ឱហ្ន៎ ! វាសនាយើងវាសនាគេ ពិតជាមើលមិនឃើញមែន រូបរាងធម្មជាតិរបស់នាងស្រស់ស្អាតយ៉ាងនេះ មិនគួរណាមកធ្លាក់ក្នុងនរកអវិចីយ៍ក្លាយជាចំណីប្រុសល្មោភកាមគុណប្រុសចាយប្រាក់បែបនេះសោះ..."។

ជាការពិតណាស់ ! សង្គមខ្មែរបច្ចុប្បន្នកំពុងមានការរីកដុះដាលយ៉ាងខ្លាំង លើបញ្ហាជួញដូរមនុស្សនេះ។ ទោះបីជារាជរដ្ឋាភិបាលបាន និង កំពុងយកចិត្ត ពួកគេមិនញញើតនឹងច្បាប់ឡើយ ថ្វីបើដឹងថា ពេលប៉ូលីសចាប់បានត្រូវមានទោសកំរិតណាក៏ដោយ។ នេះបណ្តាលមកពីជនល្មើសទាំងនោះនៅអាងខ្នងអាងអំនាច ពិសេសអាងលុយរាប់ពាន់រាប់ម៉ឺនដុល្លា យកមកទិញឧត្តមគតិរបស់ប៉ូលីសមួយចំនួនតូចដែលខ្វះការពិចារណា ខ្វះទំនួលខុសត្រូវ ខ្វះគំនិតជាតិនិយម ភ្លេចអស់តួនាទី ភារកិច្ច កាតព្វកិច្ចដែលខ្លួនត្រូវបំពេញ ត្រូវបំរើជាតិបំរើប្រជាជន។ ផ្ទុយពីមន្ត្រីប៉ូលីសមួយក្តាប់តូចនេះ ក៏នៅមានមន្ត្រីប៉ូលីសល្អៗជាច្រើនខិតខំបំពេញកាតព្វកិច្ចបានយ៉ាងប្រសើរជូនប្រជាជន រហូតភ្លេចអស់សេចក្តីសុខផ្ទាល់ខ្លួន និងសេចក្តីសុខគ្រួសារ។ ពួកគេខិតខំយ៉ាងស្វិតស្វាញបំផុតទោះយប់ក្តី ថ្ងៃក្តី អោយតែឮថា ទីណាមានអាជីវកម្មជួញដូរមនុស្សនេះកើត





ឡើង ពួកគេនឹងឆាប់រូតរះអោយឆាប់ទៅដល់ភ្លាម ។ ប៉ូលីសគំរូទាំងនេះតែងរុករកវែកមុខជនល្មើសគ្រប់ច្រកល្ហក តាំងពីនៅផ្ទះបន ផ្ទះសំណាក់ ហាងខារ៉ាអូឃេ ហាងម៉ាស្សា និង តាមសណ្ឋាគារនានាពេញទូទាំងផ្ទៃប្រទេស ។ *ការយកចិត្តទុកដាក់បំពេញការងារ តាមមាគ៌ាដឹកនាំ របស់រាជរដ្ឋាភិបាលប្រកបដោយភាពម៉ត់ចត់បែបនេះ មិនយូរមិនឆាប់សង្គមកម្ពុជានឹងប្រែក្លាយទៅជាតំបន់មួយ ដែលគ្មានការជួញដូរមនុស្ស គ្មានការធ្វើអាជីវកម្មផ្លូវភេទរួមទាំងគ្មានការរំលោភបំពានលើស្ត្រី និង កុមារទៀតឡើយ ។...*

ការរីករាយរបស់រំដួល ថានឹងបានការងារធ្វើ មានប្រាក់ខែខ្ពស់ ឥឡូវប្រហែលជាមិនអាចសម្រេចតាមបំនងរបស់នាងបានឡើយ ។.... នាងចាប់ផ្តើមងងឹតស្លុប ហើយក៏សន្លប់បាត់ស្មារតី ដោយគ្រាន់តែបរិភោគផ្លែឈើ ដែលគេយកមកអោយអម្បាញ់មិញ បានពីរបីម៉ោងប៉ុណ្ណោះ ។......

ពេលវេលាដើរលឿនណាស់ មួយប៉ប្រិចភ្នែកសោះមួយថ្ងៃក៏បានកន្លងផុតទៅ... ។ វេលាទៀបភ្លឺ ម៉ាស៊ីនត្រជាក់បានធ្វើអោយរំដួលរងារ ហើយក៏ភ្ញាក់ដឹងខ្លួន។ ប៉ុន្តែពេលនាងមើលខ្លួនប្រាណ គឺនទលគកគ្មានសំលៀកបំពាក់ជាប់នឹងខ្លួនឡើយ មិនខុសអ្វីពីសត្វផ្សោតដែលតែងលែងខ្លួនទទេនាកណ្តាលផ្ទៃនទី។ មិនតែប៉ុណ្ណោះ លោហិតពណ៌ផ្កាឈូក ជិតជាប់ក្រឡៅលើកម្រាលពូកធ្វើអោយរំដួលនាងតក់ស្លុតយ៉ាងខ្លាំងហើយទឹកភ្នែកក៏ជន់ហូរដោយមិនដឹងខ្លួន។ ពេលនេះនាងដឹងច្បាស់ណាស់ថា អ្វីដែលបានកើតឡើងមកលើខ្លួននាងក្នុងរយះ

ពេលមួយយប់នេះ។ ដោយនឹកខឹងខ្លាំងពេក ហើយអត់ទ្រាំមិនបាន នាងក៏ស្ទុះទៅខាំក្រញៅជនជាតិកូរ៉េម្នាក់ ដែលកំពុងដេកយ៉ាងស្កប់ស្កល់នៅក្បែរនេះ អោយដាច់សាច់ចេញឈាមជាច្រើនកន្លែង ហាក់បីដូចជាសត្វខ្លាស្ទុះទៅសង្គ្រប់កូនចៀមអ៊ីចឹង :

-ហេតុអីពូឯងធ្វើអំពើថោកទាបយ៉ាងហ្នឹង ?... អាក្រក់ណាស់ !... សាហាវណាស់ !... សាហាវជាងសត្វតិរច្ឆានទៅទៀត... ហ៊ឺ...

កម្លោះកូរ៉េធ្វើភ្នែកឡិងឡង់ ព្រោះមិនចេះភាសាខ្មែរ ស្តាប់មិនយល់ មិនដឹងពីអ្វីដែលនាងកំពុងនិយាយ... ដោយខ្លាចនាងខាំក្រញៅទៀត កំលោះកូរ៉េក៏ទាញទ្វារបើកចេញយ៉ាងប្រញាប់ ស្របពេលនោះអ្នកបកប្រែភាសាក៏មកដល់ហើយនិយាយពន្យល់នាង :

-នាងដឹងទេ ? ជនជាតិកូរ៉េនេះបានទិញខ្លួននាងមួយសប្តាហ៍ ពីមីងពីរនាក់កាលពីម្សិលមិញនេះ ក្នុងតម្លៃ ៨០០ដុល្លា។

ដឹងខ្លួនថាចាញ់បោកស្ត្រីមេខ្យល់ពីរនាក់នោះ រំដួលហូរទឹកភ្នែកស្រាក់ចេញពីកែវភ្នែកខ្មៅយង់គួរអោយអាណិត :

-បងមនោ !... អូនខុសចំពោះបងខ្លាំងណាស់ !... បងជាបុរសទីមួយដែលបេះដូងអូនបានដៅទុករូបបងធ្វើជាប្តីរួចទៅហើយ... ទោះបើយើងមិនទាន់រៀបការក្តីតែបេះដូងអូន... សេចក្តីស្រលាញ់របស់អូន !... បានប្រគល់ជូនបងរួចទៅហើយ... បេះដូងអូនដែលលោតរាល់ថ្ងៃនេះតែងទន្ទេញប្រាប់អូនថា បង





គឺជាប្តីរបស់អូន... តែមិនគួរឡើយបងអើយ ! ពេលនេះភាពបរិសុទ្ធរបស់អូនបានត្រូវគេបំផ្លាញខ្ទេចខ្ទីអស់ហើយ... អូនមិនអាចរក្សាភាពបរិសុទ្ធនេះជូនបងបានទៀតឡើយ... អភ័យទោសអោយអូនផង..... ហ៊ឺ..... ហ៊ឺ..... ហ៊ឺ.....

ឮសេចក្តីទួញសោកអណ្តឺតអណ្តករបស់រំដួលចាកទង អ្នកបកប្រែភាសាក៏មានចិត្តអាណិតនាងបន្តិចដែរ តែមិនដឹងធ្វើម៉េច ព្រោះខ្លួនមានឋានៈត្រឹមតែអ្នកស៊ីឈ្នួលបកប្រែភាសាឱ្យគេប៉ុណ្ណោះ។ ស្ងាត់បន្តិចទើបគាត់ដាច់ចិត្តលួង :

-បានហើយនាង ! ឈប់យំទៅ... ធ្វើម៉េចបើនាងកើតមកជាអ្នកជនបទ អ្នកស្រែ មិនអាចនឹងយល់ដឹងពីកលល្បិចបោកប្រាស់របស់អ្នកទីក្រុងបាន... *សេចក្តីល្ងង់នេះមកតែពីហេតុក្រ ឯសេចក្តីក្រនេះមកតែពីហេតុល្ងង់*..... កាត់ចិត្តបំភ្លេចរឿងនេះចោលចុះ ធ្វើម្តេចបើសុបិនកំណាចនេះមកយាយីលងបន្លាចនាងបែបនេះទៅហើយ។

ទោះឮពាក្យទូន្មានដ៏ល្អនេះក៏ដោយ ក៏ពេលនេះរំដួលមិនអាចទទួលយកបានដែរ។ នាងពោលពាក្យទាំងរអាក់រអួលពោរពេញដោយកំហឹង :

-ចេញទៅ !... ខ្ញុំមិនចង់ស្តាប់ទៀតទេ! អ្នកណាក៏ដូចជាអ្នកណាដែរ... អាក្រក់ដូចតែគ្នាហ្នឹង! កុំចាំបាច់មកនិយាយល្អអី!... ខ្ញុំលែងជឿទៀតហើយ!...

ដោយមិនអាចនិយាយលួងលោមអោយនាងយល់បាន បុរសអ្នកប្រែភាសាក៏ដើរចេញទៅ ទុកអោយនារីរងគ្រោះនៅទួញសោកម្នាក់ឯង :

-ឱម៉ែអើយ !... ជីវិតកូនអីក៏អភ័ព្វម្ល៉េះ?... តម្លៃស្ត្រី! កិត្តិយសស្ត្រី!... ពេលនេះត្រូវរលាយអស់ហើយ..... ម៉ែ !... បើម៉ែដឹងរឿងនេះ តើម៉ែពិបាកចិត្តយ៉ាងណា ? ទុក្ខព្រួយប៉ុណ្ណា ?... ម៉ែ ! តើម៉ែខឹងកូនទេ ? កេរដែលកូនទទួលពីម៉ែ... តំណក់ឈាមដ៏ថ្លៃថ្លារបស់ម៉ែ !.. ពេលនេះកូនបំផ្លាញខ្ទេចខ្ទីអស់ហើយ......

ទឹកភ្នែក ! អ្នកហូរមក ហូរអោយអស់ចិត្តចុះ ! អ្នកហូរដើម្បីជួយសម្រាលទុក្ខទោសរបស់បុប្ផារងគ្រោះម្នាក់ ដែលត្រូវស្រពោនស្វិតក្រៀមក្រំចោលបង់អស់នូវក្លិនក្លែបសុគន្ធា គ្មានថ្ងៃណានឹងអាចមានក្លិនក្រអូបសាយដូចដើមឡើយ ទោះបីជាមានទឹកសន្សើមពីសួគ៌ាមកចាំប្រស់ព្រំក៏ដោយ ។ យំយូរៗទៅ រំដួលក៏ដេកលង់លក់ដោយមិនដឹងខ្លួន......

ខណៈបើរំដួលភ្ញាក់ដឹងខ្លួនវិញ ខ្មើយដែលមុននេះនាងទ្រោបយំពីលើក៏នៅតែមិនទាន់បាត់ស្ងួតផង ។ នាងរំកិលខ្លួនតើមៗពីលើគ្រែដោយអាការៈធីងធោងអស់កម្លាំងល្ហិតល្ហៃ ថ្វីបើនាងដេកលក់មួយស្រលេតក៏ដោយ ។ ម្ងួតទឹករួចកាលណានាងមានអារម្មណ៍ត្រជាក់ខ្លួនស្រួលវិញតែនៅហេវហត់ហេងហាងបន្តិច ។ ទន្ទឹមនឹងនេះរំដួលក្រលេកឃើញចេកចៀន ដែលទើបចៀនថ្មីៗពណ៌ក្រហមក្រឡាតគួរឱ្យឆ្ងាញ់ដាក់នៅលើតុក្បែរទូសម្អាង ។ កំពុងតែឃ្លានស្រាប់ផង ឃើញចំណីមកដល់មាត់ដូច្នេះ នាងចាប់យកចេកចៀនមកទទួលទានភ្លាមភ្លេចគិតថាមុននេះនាងរងគ្រោះដោយសារអ្វី ។ កំពុងតែឆ្ងាញ់មាត់នឹងចេកចៀន





ស្រួយស្រីបក្តៅមិនទាន់នឹងអស់មួយផង ស្រាប់តែនាងសន្លប់ម្តងទៀត ពេលដឹងខ្លួនឡើង សំលៀកបំពាក់ក៏ឃ្លាតចាកកាយអស់សល់ខ្លួនទទេ ។ ដោយទ្រាំនឹងការចាប់រំលោភម្តងជាពីរដងមិនបាន រំដួលក៏លួចរត់ពីសណ្ឋាគារនោះ ហើយមកអង្គុយនៅលើបង់មាត់ទន្លេ ព្រោះមិនដឹងជាទៅណា ។ សំណាត់តូចៗអណ្តែតលើផ្ទៃទឹក ប្រៀបដូចជីវិតឥតគោលដៅ... អង្គុយយូរៗទៅ រំដួលក៏ប្រទះឃើញមីងពតដើរតាមមាត់ទន្លេ :

-មីង ! មីង !... មីងឯងទៅណា ? មីងចង់យកខ្ញុំមកបោះចោលកណ្តាលទីក្រុងអីចឹងឬ ?

មីងពតឃើញរំដួលនៅចំពោះមុខដូចនេះ ក៏អេះអុញនិយាយមិនចេញ :

-អឺ !... មីង... អឺ... នំ !..........

ឃើញមីងពតដូចមានអ្វីមកខ្ទាស់កន្ទើតបែបនេះ រំដួលក៏បន្តសំណួរ :

-មីង ! ចុះឯណាប្រាក់ខ្ញុំ ?... ប្រាក់ដែលមីងបានមក ដោយយកខ្ញុំទៅអោយម៉ាស្សាភ្ញៀវនោះអី ! (រំដួលនិយាយរបៀបចំអក) ចេះប្រើពាក្យណាស់ហ្ន៎ !.. ម៉ាស្សា !... ពិរោះមែន ! ហ៊ឺះ ! គោតមីងឯងហ៊ានធ្វើទៅរួច... ម៉ែខំទុកចិត្តលើមីងឯង មិនគួរមីងឯងក្បត់សេចក្តីទុកចិត្តនោះ ហើយបែរជាធ្វើបាបបោកប្រាស់ខ្ញុំអោយអាម៉ាស់យ៉ាងនេះសោះ ។

មីងពតនៅតែនិយាយមិនចេញ រំដួលក៏បន្ត :

-ឥឡូវបើមិនបានប្រាក់ដ៏លាមកនោះ សងខ្សែដៃឱ្យខ្ញុំវិញភ្លាមឡើង !

រំដួលខឹងផងយំផងស្ទើរឆ្កួត ឯមីងពតក៏ខំសម្រួលអារម្មណ៍ហើយងាកញញឹមយ៉ាងស្រស់ហាក់ដូចគ្មានរឿងអ្វីកើតឡើង :

-ប្រាក់នោះមីងយកលេងល្បែងអស់ហើយ... ឯងកុំភ័យ ! ទៅដល់ភូមិវិញមីងនឹងសង !... អី... មីងសុំទោសណា៎ ! មិនមែនមីងចង់ធ្វើទេ... តែមីកាភេមវាបញ្ចុះបញ្ចូលខ្លាំងពេក ដំបូងមីងមិនព្រមទេ តែវាគម្រាមមីងថា បើមីងមិនព្រមកុំសង្ឃឹមថាបានចេញពីភ្នំពេញនេះរួចនោះ វានឹងប្រើពួកអាដៃដល់ឱ្យតាមធ្វើបាបមីង ព្រោះមីងបានដឹងរឿងរបស់វានេះច្រើនពេក ។ ឈប់ខឹងទៅណារំដួល ! មីងខុសហើយ... អោយមីងសុំទោស !......

រំដួលរាងទន់ចិត្តនឹងពាក្យលួងលោមដោះសារ ដ៏គួរអោយអាណិតរបស់មីងពត :

-មីង ! ខ្ញុំអស់ភាពបរិសុទ្ធហើយ... តើអោយខ្ញុំទៅជួបម៉ែដូចម្ដេចទៅ ? មីង !... ហ៊ឺ... ជួយប្រាប់ខ្ញុំផង... តើខ្ញុំគួរធ្វើម៉េច ?......

ទឹកភ្នែករាប់ម៉ឺនតំណក់ រមៀលធ្លាក់កាត់ជ្រលងផែនថ្ពាល់ម្ដងទៀតហើយ ។ មីងពតស្ទង់ទឹកចិត្តនាងដឹងថា នាងកំពុងមានទំនុកចិត្តមកលើគាត់វិញហើយ ហេតុនេះគាត់ក៏តប :

-មិនអីទេ ! ចាំមីងជួយដោះស្រាយអោយ ឯងកុំបារម្ភពេក... ឥឡូវល្ងាចហើយ ទៅរកផ្ទះជួលដេកមួយយប់សិន ។ ចាំស្អែកមីងនាំទៅរករោងចក្រកាត់ដេរធ្វើការដើម្បីបានកំរៃខ្លះ គ្រាន់ធ្វើសោហ៊ុយតាមរកឪពុកឯង ។





ហេតុតែសម្ដីផ្អែម ពាក្យពេចន៍លន់តួអង្វរកច្រើនពេក រំដួលក៏ទន់ចិត្តហើយក៏ទៅតាមសម្ដីបោកប្រាស់ទាំងងងើលម្ដងទៀត ។

## វគ្គទី៣

# ផ្ទះបនមិនមែនជាឋានសួគ៌

ព្រះសុរិយាបរាជរថផុតខ្ពស់លើសំណង់អគារធំៗ ដោយខំបញ្ចេញកាំរស្មីពណ៌មាសក្រហមឆ្អៅ ចាំងជះពន្លឺខ្លាំងឡើងៗពីទិសបូព៌ា ។ តាមផ្លូវក្រាលគ្រួសក្រហម អ្នកលក់ដូរកំពុងដុតដៃដុតជើង នឹងមុខរបររបស់ខ្លួនដែលមានកម្មករ កម្មការិនីយ៉ាងច្រើនស្មេកស្មុះ ប្រជ្រៀតគ្នាដើរទិញចំនី គ្រាន់ទ្រាប់ក្រពះមុនចូលធ្វើការ ។ ជាមួយគ្នានោះ មីងពតនាំរំដួលដើររលះរលាំងសំដៅចូលរោងចក្រដែរ។ ប៉ុន្តែមុននឹងចូលទៅ គាត់នាំនាងទៅញ៉ាំនំបញ្ចុកក្បែរនោះសិន។ កំពុងតែឃ្លានស្រាប់ផង រំដួលនាងខំកាយញាត់ៗបំពេញសេចក្ដីស្រេកឃ្លានភ្លេចគិតអស់ពីល្បិចកលទាំងឡាយ ។ឆ្ងាញ់ណាស់ ! រំដួលជក់មាត់នឹងនំបញ្ចុកសំលខ្មែរ តែអកុសលលោកអើយ !... នាងមានអាការៈដូចមុនទៀតហើយ... ងងឹតមុខស្លុប ! ទន់ដៃទន់ជើង ហើយក៏ទន់ត្របកភ្នែកដេកដួលលើមីងពត ។ សប្បាយចិត្តណាស់ ! ស្រីកំពូលល្បិច ប្រញាប់ប្រញាល់ដឹករំដួលយកទៅលក់អោយថៅកែស្រីខូចនៅទួលគោកតែម្ដង ដោយភូតកុហក អ្នកដែលចោមរោមមើលរំដួលសន្លប់ថា យកទៅមន្ទីរពេទ្យ ហើយប្រាប់ថានាងមិនអីទេនាងខ្សោយតែយ៉ាងនេះតាំងពីតូច ។......





នៅក្នុងបន្ទប់មួយដ៏វិចិត្រ ដែលរចនាដោយវាំងននពណ៌លឿងខ្ចីរំដួលកំពុងក្រាបយំលើពូកយ៉ាងខ្សឹកខ្សួល កែវភ្នែកដ៏ខ្មៅស្រទន់ កាលបើរលីងរលោងដោយទឹកភ្នែកយ៉ាងនេះ កាន់តែធ្វើឱ្យយើងស្រណោះនាងថែមទៀត ។ ឯណាទៅអនាគតនារីខ្មែរ ! ឯណាទៅអនាគតនារីស្លូតត្រង់ ! តើឱ្យស្ត្រីវេទនារស់នៅដោយរបៀបណា បើអ្វីដែលជាទីស្រលាញ់ អ្វីដែលជាទីសំណប់ត្រូវគេបំផ្លិចបំផ្លាញអស់យ៉ាងនេះ ?... មិនតែប៉ុណ្ណោះគេចាត់ទុកស្រីទាំងនោះដូចជាសត្វជ្រូកមាន់ទា ដែលអាចអោយគេជួញដូរចុះឡើង ពីកន្លែងមួយទៅកន្លែងមួយ ហើយដាក់ឃុំឃាំងមិនអោយចេញទៅណារួច មិនខុសអ្វីពីសត្វធាតុដែលម្ចាស់ តែងធ្វើរបងដាក់ក្នុងទ្រុងមិនអោយរត់គេចអីចឹងដែរ។ គិតទៅ ! ជនល្មើសទាំងនោះហាក់មិនខ្លាចញញើត នឹងអាជ្ញាធរមានសមត្ថកិច្ចសោះពួកគេប្រឹងធ្វើទាំងគឃ្លើន បំពានលើច្បាប់រដ្ឋធម្មនុញ្ញ បំពានលើសីលធម៌សង្គម មិនតែប៉ុណ្ណោះបំពានទៅលើសីលធម៌ព្រះពុទ្ធសាសនា ដែលជាសាសនារបស់រដ្ឋថែមទៀតផង ។ អាស្រ័យដោយរដ្ឋធម្មនុញ្ញ គ្រាន់តែជាច្បាប់គោលៗ ដែលថែងជាទូទៅមិនទាន់គ្រប់គ្រាន់ក្នុងការគ្រប់គ្រងប្រទេស ទើបរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ត្រូវចងក្រងតាក់តែងច្បាប់ផ្សេងៗទៀត ដើម្បីលំអិតទៅលើផ្នែក ឬវិស័យនីមួយៗដូចជា ច្បាប់ពាណិជ្ជកម្ម ច្បាប់ស្ដីពីការងារ ច្បាប់ការពារបេតិកភ័ណ្ឌវប្បធម៌ ច្បាប់ស្ដីពីសិទ្ធិមនុស្ស និង ច្បាប់ដទៃទៀតជាច្រើន ។ ទន្ទឹមនឹងច្បាប់ទាំងនេះបានអនុម័តឡើង ច្បាប់ស្ដីពីការបង្ក្រាបអំពើពង្រត់ និងលក់

ដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្ស ក៏ត្រូវបានអនុម័តឡើងដែរ តាំងពី *ថ្ងៃទី ១៦ ខែ មករា ១៩៩៦* មកម្ល៉េះ ។ ច្បាប់នេះបានចែងយ៉ាងច្បាស់ថា *បើជនណាអូសទាញមនុស្សទោះប្រុសក្តី ស្រីក្តី នីតិជន រឺ អនីតិជន មានសញ្ជាតិអ្វីក៏ដោយ ដោយវិធីលួងលោមសន្យាអោយប្រាក់កាស គ្រឿងអលង្កា រឺ វិធីណាក៏ដោយ ទោះបីសាមីខ្លួនសុខចិត្ត រឺ មិនសុខចិត្ត ដោយវិធីបង្ខិតបង្ខំគំរាមគំហែង រឺប្រើថ្នាំសណ្តំស្មារតី និង សតិអារម្មណ៍ ដើម្បីពង្រាត់យកទៅលក់ រឺយកទៅធ្វើពេស្យាចារ ជននោះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ១០ឆ្នាំ ដល់ ១៥ឆ្នាំ តែបើជនរងគ្រោះជាអនីតិជនអាយុតិចជាង ១៥ឆ្នាំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ឆ្នាំ ដល់ ២០ឆ្នាំ។ មិនតែប៉ុណ្ណោះ ចំពោះជនណាដែលបើកកន្លែងសំរាប់ប្រព្រឹត្តអំពើអនាចារ រឺអំពើអាសអាភាសផ្សេងៗ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ០១ឆ្នាំ ដល់ ០៥ឆ្នាំ និង ពិន័យជាប្រាក់ពី ៥ ០០០ ០០០ រៀល (ប្រាំលានរៀល)ដល់ ៣០ ០០០ ០០០ រៀល (សាមសិបលានរៀល។ តែបើជនល្មើសនៅតែមិនរាងចាល ត្រូវផ្តន្ទាទោសទ្វេជាពីរ ។*

-ច្បាប់ ! ច្បាប់ ! ច្បាប់ !... តើអ្នកនៅសំងំស្ងៀមធ្វើអ្វី ? ម្តេចមិនទៅចាប់ ជនល្មើសទាំងនោះញាត់គុកទៅ ? សូមអ្នកកុំអោយអំពើឧក្រិដ្ឋ អំពើល្មើស និង អំពើយុត្តិធម៌ ជាន់ឈ្លីបំផ្លាញតំលៃ និងអំនាចរបស់អ្នកអោយសោះ !... សង្ឃឹមថាអ្នកនឹងស្វែងរកសេចក្តីយុត្តិធម៌ និងអនាគតភ្លឺស្វាងជូនដល់បុប្ផារងគ្រោះម្នាក់នេះបានចុះ !.....





នៅក្នុងបន្ទប់ចាក់សោជិត រំដួលហាក់ដូចជាអ្នកទោសម្នាក់ ដែលត្រូវគេឃុំឃាំងបណ្តោះអាសន្នសំរាប់រង់ចាំការកាត់ក្តីពីចៅក្រម ។ ទោះនាងចេញទៅណាមកណា ក៏ស្រ្តីមេបនមិនព្រមដែរ ព្រោះខ្លាចនាងលួចរត់។ ទោះបីនាងស្រែកយំឱ្យទឹកភ្នែកហូរជោរជន់លិចនគរខ្មែរទៀត ក៏គេមិនអើពើនឹងទំនួញសោករបស់នាងដែរ។ មេបននេះបង្ខាំងនាងទុក ព្រោះស្មានថានាងនៅក្រមុំព្រហ្មចារិយ៍ ដឹងអីស្ត្រីមេបនក៏ត្រូវមីងពតបោកបញ្ឆោតដែរ។ ស៊ីងតែគ្រប់ផ្ទះបនទៅហើយ ដែលគេតែងស្វែងរកក្តាមស្រែក្រមុំៗទុកសំរាប់អ្នកមានប្រាក់ និងអ្នកមានឋានៈខ្ពស់ដោយហេតុថានៅក្រមុំដូចនេះ អាចលក់បានតំលៃខ្ពស់ខ្លាំងណាស់ ។...... យប់ទីបីនៃការឃុំឃាំង ដោយទ្រាំមិនបាននឹងការរស់នៅដូចសត្វធាតុ ដែលគេដាក់ក្នុងទ្រុងនោះ នារីស្រុកស្រែក៏ស្រែកទ្រហោយំអោយគេដោះលែង :

-លែងខ្ញុំទៅ ! លែងខ្ញុំទៅ ! ម៉េចក៏ចាប់ខ្ញុំឃុំឃាំងយ៉ាងនេះ ?

ខ្ញុំចង់ទៅផ្ទះវិញ ! លែងខ្ញុំទៅ ! លឺសំលេងស្រែកនាយបឹនអ្នកដែដល់ប្រចាំផ្ទះបននេះ ក៏ចាក់សោរុញទ្វារលាន់សូរក្រាក :

-នែ៎ ! មីក្តាមស្រែ !.... នាងឯងខំស្រែកយំ ជំទាលរកងាប់អី ? ចង់ឈឺសាច់ណាស់ឬ ?

បុរសមាឌធំខ្មៅក្រអាញ លេចប្រាកដមកចំពោះមុខនាង បន្ទាប់ពីពួសំលេងរុញទ្វារអោយរបើករូចមក ។ ពេលនោះរំដួលក៏ជំរុះវាចា :

-លែងខ្ញុំទៅ !.... ខ្ញុំសូមអង្វរ.... កុំធ្វើបាបខ្ញុំអី ! ជួយនាំខ្ញុំចេញផង!..... ខ្ញុំនឹងមិនភ្លេចគុណអ្នកទេ !

-យី ! លែងអីក៏ងាយម្ល៉េះ ! នាងឯងមានដឹងទេថា យើងអស់លុយច្រើនប៉ុណ្ណាទំរាំទិញក្បាលនាងឯងបាននោះ ! តិចណាស់ក៏ ២០០ដុល្លា ដែរ យើងប្រាប់ឱ្យហើយទៅ ! នេះមិនទាន់បានបំរើភ្ញៀវម្តងផង ចង់អោយយើងដោះលែងទៀត !

នាយបឺនសំលុតនាងបណ្តើរ ចាប់ផ្តួលនាងលើគ្រែបណ្តើរ ធ្វើឱ្យរំដួលញ័រខ្លួនទទ្រើកខំអង្វរទាំងញ័រមាត់ :

-កុំ ! កុំធ្វើបាបខ្ញុំ !....... លែងខ្ញុំទៅ........ បើប្អូនស្រី បងស្រីអ្នកឯងត្រូវគេធ្វើបាបបែបនេះវិញ តើអ្នកឯងឈឺចាប់ទេ ?

បឺនចង្អុលមុខនាងដោយបើកភ្នែកសំឡឹងថ្លែត :

-កុំបានសម្តីពេក ! យើងប្រាប់ឱ្យហើយណាំ បើហ៊ានតែស្រែកទៀត យើងប្រាប់ថៅកែស្រីឱ្យបើកដៃឱ្យយើងហើយ ! បើមិនស្តាប់ប្រយ័ត្នឈឺសាច់ រឺប្រយ័ត្នយើងចាប់រំលោភទាល់តែងាប់ !

បឺនបុរសកំនាច និយាយចប់ដោយបញ្ចេញខ្យល់គំហកលឺសូរឈិះ ! ហើយទាញទ្វារបិទគ្រឹប ដោយទុកឱ្យបុប្ផារុះរោយនៅអង្គុយយំឱបក្បាលជង្គង់សំរក់ទឹកភ្នែក :





-ម៉ែ !... បងមនោសំលាញ់ចិត្ត ! តើបងនិងម៉ែដឹងទេ ? ថាខ្ញុំកំសត់ណាស់ !...... វេទនាណាស់ ! ខ្ញុំជាមនុស្សសោះ តែត្រូវគេចាប់ឃុំដូចសត្វតិរច្ឆាន...... អនាគតខ្ញុំត្រូវរលាយអស់ហើយ....... បងមនោ ! អូនប្រហែលខានបានឃើញមុខបងទៀតហើយ... ពីថ្ងៃនេះទៅអូននិងបងហាក់បីដូចជាកំពុងនៅភពផ្សេងគ្នាអ៊ីចឹង.... គ្មានថ្ងៃណា វេលាណា ដែលអាចអោយយើងបានជួបគ្នាវិញនោះទេ... បងអើយ !... ស្រទាប់ផ្កាំរំដួលដែលស្លោកស្រពោនទៅហើយនេះកំពុងតែរសាត់អណ្តែតទៅតាមកំលាំងព្យុះដ៏កំនាច ដែលបោកបក់បំបែកផ្កាអោយចាកទង ហើយឃ្លៀងឃ្លាតចេញពីដើម បន្តដំនើរកាន់តែឆ្ងាយចេញពីដីកំនើតហើយ......

ដប់ថ្ងៃក្រោយមក រំដួលនៅតែត្រូវគេឃុំក្នុងបន្ទប់នោះដដែល ។ រយៈពេលប៉ុន្មានថ្ងៃនេះ ធ្វើអោយនាងដឹងថា ការងារក្នុងផ្ទះបនគឺជាការងារធ្ងន់ធ្ងរ ហើយក៏មិនមែនជាឋានសួគ៌ ដូចដែលស្ត្រីពេស្យាខ្លះបានគិតនោះទេព្រោះថាផ្ទះបននៅភ្នំពេញតែងមានជួបនូវគ្រប់រសជាតិ គ្រប់រូបភាពទាំងអស់ដូចជាស្រវឹងស្រា វាយតប់ទាត់ធាក់ គំរាមកំហែងគ្រប់បែបយ៉ាង និងធ្វើអ្វីប្លែកៗដែលជីវិតនាងមិនដែលជួបប្រទះ ហើយសុទ្ធតែជាអំពើថោកទាបទាំងអស ។ ជាពិសេសគឺមេបនតែងតែកាត់ប្រាក់ មិនអោយអាហារគ្រប់គ្រាន់ ពេលឈឺមេបនមិនដែលយកចិត្តទុកដាក់ ជួយព្យាបាលម្តងណាទេ ។ ប៉ុន្តែហេតុការណ៍ទាំងនេះ ពុំទាន់កើតឡើងលើផ្ការំដួលទេ ព្រោះកាលៈទេសៈពុំទាន់ហុច

ឱ្យមេបន ។ ម្តងជាពីរដង រំដួលត្រូវលង់ខ្លួនចាញ់បោកគេដដែល នោះក៏ព្រោះតែនាងមិនបានទទួលការអប់រំរៀនសូត្រឱ្យបានវែងឆ្ងាយដូចគេដូចឯងនោះទេ គឺនាងត្រូវម្តាយឱ្យឈប់រៀនតាំងពីថ្នាក់ទីបីម្ល៉េះ ។ ការដែលរំដួលក៏ដូចជាកូនស្រីខ្មែរទូទៅ មិនបានរៀនសូត្រ និងមិនបានបន្តការសិក្សាវែងឆ្ងាយ គឺដោយសារមានកត្តាជាច្រើន ដែលតែងតែបង្កជាឧបសគ្គដល់ការអប់រំរបស់ស្ត្រី។ *ទំនៀមទំលាប់គឺជាកត្តា មួយដែលមាតាបិតាខ្មែរប្រកាន់ខ្ជាប់បំផុត ។* លោកឪពុកអ្នកម្តាយ តែងទុកអោយកូនស្រីនៅជួយកិច្ចការមេផ្ទះ ជាជាងការឱ្យកូនស្រីទៅរៀន ព្រោះគេយល់ថាការងារផ្ទះបាយ ជាការរៀនសូត្ររបស់កូនស្រីដែលត្រូវតែចេះមុននិងក្លាយជាភរិយា រឺម្តាយរបស់គេ ។ កូនស្រីត្រូវធានារ៉ាប់រងជីវភាពគ្រួសារទាំងមូល ដោយត្រូវនៅផ្ទះលក់ដូរឥវ៉ាន់ ដើរលក់ផ្កា លក់ចំនី រឺលក់របស់ក្មេងលេង ដើម្បីរកប្រាក់ចំនូលបន្ថែម សំរាប់ផ្គង់ផ្គង់ជីវភាពគ្រួសារ ។ មិនតែប៉ុណ្ណោះ កុមារីត្រូវរ៉ាប់រងកិច្ចការសព្វសារពើ ជំនួសមាតាបិតាដូចជា ថែរក្សាប្អូន រឺចាត់ចែងការងារផ្សេងៗ មានដូចជាលាងចានឆ្នាំ ដាំបាយបោសសំអាតផ្ទះ បោកគក់សំលៀកបំពាក់ជាដើម ។ ដោយសារតែធ្លាប់អនុវត្តតៗគ្នាមកដូច្នេះ ទើបឪពុកម្តាយខ្មែរមិនដែលផ្តល់ឱកាសអោយកូនស្រីបានចូលរៀនទេ គេគ្រាន់តែធ្វើទៅតាមទំនៀមទំលាប់ ដែលដូនតាធ្លាប់ធ្វើពីមុនមកប៉ុណ្ណោះ ។ *ស្ថានភាពជីវភាព រឺការចំណាយលើការរៀនសូត្រ ក៏ជាកត្តាមួយដែលធ្វើអោយឪពុកម្តាយខ្មែរ ទុកអោយកូនស្រីនៅផ្ទះដែរ ។* ដោយហេតុថា





ការចំនាយលើកូនស្រីច្រើនជាងកូនប្រុស ហើយដោយជីវភាពខ្វះខាត មាតាបិតាត្រូវធ្វើជំរើស ផ្តល់អាទិភាពអោយកូនប្រុសជាមុន ។ ប្រការសំខាន់នោះបើទុកកូនស្រីអោយនៅផ្ទះគឺមានប្រយោជន៍ជាងកូនប្រុស ។ ជាធម្មតាកូនស្រីនៅផ្ទះមិនដែលទំនេរទេ គេតែងជួយធ្វើនេះធ្វើនោះឪពុកម្តាយជានិច្ច មិនដូចជាកូនប្រុសដែលគិតតែដើរលេង រឺមិនចេះធ្វើកិច្ចការទាំងនោះឡើយ ព្រោះគេយល់ថា ការងារផ្ទះភាគច្រើនជាការងាររបស់ស្ត្រី ។ *បញ្ហាទីតាំងសាលារៀនគឺជាកត្តាមួយទៀតដែលឪពុកម្តាយ តែងមានការព្រួយបារម្ភពីសុវត្ថិភាពកូនស្រី ។* កាលបើសាលារៀននៅឆ្ងាយផ្លូវលំបាកក្នុងការធ្វើដំនើរ ពេលវេលាក៏ត្រូវចំនាយច្រើនដែរ ជួនទៅក៏ទៅរៀនទាន់ម៉ោងជួនទៅក៏ទៅមិនទាន់ម៉ោងហើយបើកង្វះមធ្យោបាយធ្វើដំនើរទៀត អត្ថិភាពទៅរៀនរបស់កូនស្រីក៏ត្រូវបាត់បង់ និងហោចខ្ចីទៅដែរ។ ជាងនេះទៅទៀត បញ្ហាទីតាំងសាលារៀននេះធ្វើឱ្យឪពុកម្តាយព្រួយបារម្ភច្រើនពីភាពអសន្តិសុខ ដូចជាការជួញដូរផ្លូវភេទការរំលោភ ការចាប់ជំរិត ការឆក់ប្លន់ជាដើម ។ *ចំនែកបញ្ហាវប្បធម៌ដែលឪពុកម្តាយគ្រប់រូបតែងប្រកាន់ខ្ជាប់មិនអោយខុសឆ្គង ក៏បានចោទជាកត្តាមួយសំរាប់រាំងស្ទះដល់កូនស្រី មិនអាចអោយចូលរៀនបានដែរ ។* ជាក់ស្តែងក្នុងសង្គមឥស្លាមគេមិនអនុញ្ញាតិអោយកូនស្រីរៀនជាមួយគ្រូប្រុសឡើយ ។ រីឯសង្គមខ្មែរជំនាន់មុនមានគ្រូបង្រៀនជាព្រះសង្ឃ ដូច្នេះកូនស្រីមិនអាចស្និទ្ធស្នាលជាមួយគ្រូបានទេ ។ កង្វះខាតគ្រូស្រីនិងគ្រូជាគ្រហស្ថក្នុងការបង្រៀនសិស្ស

ជាឧបសគ្គមួយចោទចំពោះវប្បធម៌ទាំងនេះខ្លាំងណាស់ ។ ប្រការមួយទៀតនោះ ឪពុកម្ដាយ តែងបង្ខាំងកូនស្រី ទុកអោយរៀបការទាំងនៅក្មេងខ្ចី ដែលជាវ័យមួយត្រូវទទួលការអប់រំ តែបែរជាត្រូវមករៀបការទៅវិញ ។ ដូចនេះកូនស្រីក៏ត្រូវវប្បធម៌រាំងខ្ទប់ មិនអោយបានចូលរៀនសូត្រ និងមិនអាចបន្តការសិក្សាអោយបានវែងឆ្ងាយផងដែរ ។ *ជាងនេះទៅទៀត បុរេនិច្ឆ័យក៏ជាកត្តាចំបងមួយ ដែលធ្វើអោយការរៀនសូត្ររបស់កូនស្រីត្រូវរាំងស្ទះដែរ* ។ តួយ៉ាងនៅក្នុងសង្គមខ្មែរ គេតែងមានទស្សនៈវាយតំលៃថា ***ស្រីបង្វិលជើងក្រានមិនជុំ*** *វី មានកូនស្រីដូចមានបង្គន់នៅមុខផ្ទះ វី ថាមានកូនស្រីពិបាកណាស់ ញីញ៉ញ៉ីញ៉ មុជមិនជ្រៅទៅមិនឆ្ងាយ* ។ មិនត្រឹមប៉ុណ្ណោះទេ ទស្សនៈមួយទៀតដែលឪពុកម្ដាយខ្មែរ និងប្រជាជនទូទៅតែងលើកមកនិយាយរំលឹកពីការយល់ឃើញរបស់ចាស់ទុំខ្មែរបុរាណគឺ ***កូនស្រីរៀនចេះទៅ ខ្លាចចេះសរសេរសំបុត្រអោយសង្សារ*** ។ អាស្រ័យដោយមានបុរេនិច្ឆ័យបែបនេះហើយ ទើបឪពុកម្ដាយខ្មែរខំរក្សាកូនស្រីទុកនៅក្បែរខ្លួន មិនហ៊ានអោយឃ្លាតពីភ្នែកឡើយ ។ តែបើមានកូនស្រី របស់គ្រួសារណាមួយក្នុងភូមិបានទៅរៀន គ្រួសារនោះតែងតែទទួលពាក្យនិន្ទា ពេបជ្រាយ រិះគន់ពីអ្នកភូមិជាក់ជាមិនខាន ។ កត្តាទាំងនេះហើយទើបធ្វើអោយស្ត្រីកម្ពុជាទទួលរងគ្រោះយ៉ាងធ្ងន់ធ្ងរពីសំនាក់សង្គម ពិសេសគឺភាពល្ងង់ខ្លៅ មិនចេះអក្សរនេះឯង ។ គេប្រហែលជាមិនបានគិតទេថា ***ការអប់រំស្ត្រីមួយនាក់ គឺអប់រំប្រជាជាតិទាំងមូល*** ។ ***ស្ត្រីជាមាតានិងជាភរិយាម្នាក់ គឺជា***





***កោសិកាមួយនៃគ្រួសារ ហើយគ្រួសារជាកោសិកាមួយរបស់សង្គម*** ។ បើស្ត្រីមានការអប់រំ មានចំនេះដឹង គេនឹងអាចយកចំនេះនោះ ទៅអប់រំទូន្មានដល់កូនប្ដី មិនអោយប្រព្រឹត្តអំពើអ្វី ដែលគ្មានសីលធម៌ ខុសច្បាប់ រហូតបំផ្លាញសង្គមជាតិអោយអាប់អោនដោយសារខ្លួនឡើយ ។ ***ហេតុនេះបើស្ត្រីម្នាក់អប់រំគ្រួសារមួយអោយបានល្អ ស្ត្រីមួយនគរនឹងអាចអប់រំប្រទេសជាតិមួយអោយបានរីកចំរើនថ្កុំថ្កើងជាក់ជាមិនខាន*** ។

...... ប៉ុន្មានថ្ងៃក្រោយមក ស្រាប់តែមានអ្នកធំម្នាក់ដែលមានឋានៈជាចៅហ្វាយស្រុកនៅខេត្តកណ្ដាល បានចូលមកដល់ផ្ទះបននេះ ។ ថៅកែស្រីគ្រាន់តែក្រលេកឃើញភ្លាម ក៏ស្ទុះរឹងទៅទទួលរាក់ទាក់ :

-អស្ចារ្យ ! ថ្ងៃនេះកន្លែងខ្ញុំពិតជាមានកិត្តិយសបំផុត ដែលលោកចៅហ្វាយស្រុកមកកំសាន្តលេង ។

ចៅហ្វាយស្រុកញញឹមជ្រួញចិញ្ចើម :

-កូនស្រីអ្នកទៅណាបាត់អស់ហើយ ? ហើយមានមកថ្មីទេ ?

ពាក្យថា " កូនស្រី " នេះ គឺសំដៅទៅលើស្រីៗ ដែលជាអ្នកបំរើកាមគុណដល់បុរសជាភ្ញៀវ មិនមែនសំដៅលើកូនស្រីបង្កើតរបស់ថៅកែនោះទេ ។ កំពុងតែចាំឱកាសនេះផង ស្ត្រីមេបនក៏ឆ្លើយទាំងញញឹមញញែម :

-ចាំ ! មានហើយស្អាតណាស់ ជាក្ដាមស្រែទើបតែចាប់មកថ្មីៗ មិនទាន់ទាំងបាត់ក្លិនផុកផង ! ហ៊ានធានាថា លោកពិតជាពេញចិត្ត !

ចៅហ្វាយស្រុកញញឹមស្រាលហើយបង្អួរសំដី :

-អោយតែដូចមាត់ថៅកែចុះ! ប៉ុន្មានក៏ខ្ញុំហ៊ានដែរ អោយតែនៅហ្ស៊ីន! ម៉េច១កុំបោកប្រាស់ខ្ញុំណាំ ! ថៅកែស្រីធ្វើឫកម្ញឹកម៉ូក់ហើយអះអាង :

-ខ្ញុំសូមធានា ១00% គឺ ១00% មិនអោយបាត់មួយភាគទេ ! សូមលោកចៅហ្វាយចាំមួយភ្លែត ខ្ញុំទៅហៅនាងមកអោយ ។

ថាហើយស្ត្រីមេបនក៏រវាសរវៃ ឡើងទៅហៅរំដួលនៅបន្ទប់ខាងលើ តែមុននឹងទៅគាត់ហៅពួកស្រី១ អោយលើកស្រាបៀរ និងគ្រឿងក្លែមមកជូនភ្ញៀវសិន ។ ផ្ទះបននេះ ថ្វីបើមើលពីក្រៅមកឃើញតូច ហើយស្ងប់ស្ងាត់ តែបើចូលមកដល់ក្នុងនោះទើបដឹងថាអស្ចារ្យ ! ទោះបីជារង្គសាលធំ១មួយចំនួននៅភ្នំពេញ ក៏សឹងប្រៀបមិនបានដែរ ។ បន្ទប់លំហែរ បន្ទប់ផឹកស៊ី បន្ទប់រាំកំសាន្តសុទ្ធតែប្រកបដោយម៉ាស៊ីនត្រជាក់ និងមានភ្លើងចំរុះពណ៌គ្រប់បែបយ៉ាងបង្កើតអោយមានផាសុកភាពបំផុត ។... បន្ទាប់ពីបានហៅរំដួលឱ្យមកឈរនៅចំពោះមុខចៅហ្វាយស្រុករួចមក បេះដូងបុរសចំនាស់ដែលមានអាយុជាងសែសិបឆ្នាំឬយហើយនោះ ក៏ស្រាប់តែញាប់ញ័រព្រឺព្រួចកាមារម្មណ៍ភ្លាម ហាក់បីដូចជាដួងចិត្តរបស់បុរសកំលោះ និងនារីក្រមុំ ដែលទើបតែជួបគ្នានារាត្រីក្រេបចំនួនទឹកឃ្មុំដំបូង ។ ឃើញភ្ញៀវកំពុងតែភាំងភ្លឹកនឹងសំរស់ទេពធីតាកណ្តាលរាត្រីសួគ៌ា ស្ត្រីមេបនក៏ជំរុះវាចា :





-ម៉េចហើយលោកចៅហ្វាយ ! នឹងបែបពេញចិត្តស្លុកហើយមើលទៅ បានជាអង្គុយភ្លឹកដូចមនុស្សអត់វិញ្ញាណ អីចឹង?

ឮសំដីចំអន់របស់ថៅកែស្រី ចៅហ្វាយស្រុកភ្ញាក់កន្ត្រាក់អារម្មណ៍ហើយសើចញឹម១ :

-បាទ ! ហួសពីពេញចិត្តទៅទៀត ! រង្វង់មុខមូលក្លំសមនឹងដងខ្លួនរាងរៀវ សក់រលោងដូចសរសៃសូត្រពណ៌ខ្មៅក្រិប រំភាយរំសាយគ្របខ្នងត្រឹមចង្កេះដូចស្លាបសត្វភូមរី ។ ភ្នែកទាំងគូខ្មៅស្រិលដូចនិលរត្នន៍ និស្ស័យសំលឹងចំស្រទន់គួរអោយប្រុស១ដាក់មុខចុះចាញ់ ហើយមានអារម្មណ៍មិនស្រួល ច្រមុះស្រួចដូចកូនកាត់ តាំងបន្ទបខ្ពស់ លើបបូរមាត់រាងក្លែបក្រួច ពណ៌ក្រហមដូចសំបកប៉េងប៉ោះទុំ ទំនងគួរអោយចង់បឺតជញ្ជក់......

មាណវី ដែលមុននេះឈរស្រគត់ស្រគំ ស្ងៀមទ្រឹងដូចរូបចំលាក់ កាលបើលឺបុរសចាយសំដីពោលពាក្យដូចនេះនាងក៏បង្ហើរផ្កាវាចាទាំងក្ដក់ក្ដាញ់ :

-នែលោក ! តើលោកជាកវីនិពន្ធឬអី បានជាមកពិពណ៌នាលែបខាយសំដីដូចទឹកសំអុយហូរចូលលូដូច្នេះ ?

ថៅកែបនលឺសំដីរំដួលដូចនេះក៏គំហក :

-នែរំដួល ! សំដីអីក៏គ្មានគួរសមបន្តិចសោះ ! គ្មានដឹងខ្ពស់ដឹងទាបអីមែន !... (ថាហើយមេបនងាកមករកចៅហ្វាយស្រុក) ... សូមទោសផងណា